D164/3/2

# នៅចំពោះមុខអង្គបុរេជំនុំជម្រះ
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**ព័ត៌មានពិស្តារនៃការដាក់ឯកសារ**

សំណុំរឿងលេខៈ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ~~២៤ និង~~២៥)

ដាក់ទៅៈ អង្គបុរេជំនុំជម្រះ

ថ្ងៃដាក់ៈ ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩

ភាគីអ្នកដាក់ៈ ការិយាល័យសហព្រះរាជអាជ្ញា

ភាសាដើមៈ អង់គ្លេស

ឯកសារទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/Date de reception): 10 / 08 / 2009
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

**ចំណាត់ថ្នាក់ឯកសារ**

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ** **សាធារណៈ**

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយការិ.សហចៅក្រមស៊ើបអង្កេត ឬ អង្គជំនុំជម្រះ**

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ**

ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ

ឈ្មោះមន្ត្រីដែលបានពិនិត្យៈ

ហត្ថលេខាៈ

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 11 / 08 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

---

**ចម្លើយតបរួមរបស់សហព្រះរាជអាជ្ញា ទៅនឹងបណ្តឹងឧទ្ធរណ៍របស់ អៀង ធីរិទ្ធ, នួន ជា, ខៀវ សំផន និង អៀង សារី ប្រឆាំងនឹងដីកាសម្រេចរបស់សហចៅក្រមស៊ើបអង្កេត ដែលបដិសេធសំណើរួមរបស់មេធាវីការពារក្តី សុំឲ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ**

---

| អ្នកដាក់ឯកសារៈ | អ្នកទទួលឯកសារៈ | |
|---|---|---|
| | | មេធាវីដើមបណ្តឹងឧទ្ធរណ៍ |
| ការិ.សហព្រះរាជអាជ្ញា | សហព្រះរាជអាជ្ញា | ខៀវ សំផន |
| លោកស្រី ជា លាង | មេធាវីដើមបណ្តឹងឧទ្ធរណ៍ | លោក សរ សុវាន |
| លោក Robert PETIT | អៀង ធីរិទ្ធ | លោក Jacques VERGES |

លោក យ៉េត ចរិយា
លោក William SMITH
លោក ពេជ្រ សម្បត្តិ
លោក Tarik ABDULHAK

លោក ផាត់ ពៅស៊ាង
លោកស្រី Diana ELLIS

**មេធាវីដើមបណ្តឹងឧទ្ធរណ៍**
**នួន ជា**
លោក សុន អារុណ
លោក Victor KOPPE
លោក Michel PESTMAN

**មេធាវីដើមបណ្តឹងឧទ្ធរណ៍**
**អៀង សារី**
លោក អាង ឧត្តម
លោក Michael G.KARNAVAS

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

*សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ២៤ និង២៥)*

D164/3/2

# សេចក្ដីផ្ដើម និង បដ្ឋនាលិខិត (សំណើ)

១. នេះជាចម្លើយតបរួមទៅនឹងបណ្ដឹងឧទ្ធរណ៍ដែលបានដាក់ដោយ អៀង ធីរិទ្ធ, នួន ជា និង ខៀវ សំផន (**"បណ្ដឹងឧទ្ធរណ៍១"**) និងបណ្ដឹងឧទ្ធរណ៍ដែលបានដាក់ដោយ អៀង សារី (**"បណ្ដឹងឧទ្ធរណ៍២"**) (ដែលបណ្ដឹងឧទ្ធរណ៍ទាំងពីរហៅថា (**"បណ្ដឹងឧទ្ធរណ៍"**) ដែលតវ៉ាប្រឆាំងនឹងដីកាសម្រេចចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ (**"ដីកាសម្រេច"**) ធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេតដែលបានបដិសេធសំណើរួមរបស់មេធាវីការពារក្ដី សុំឲ្យបំពេញកិច្ចស៊ើបសួរ ទាក់ទងនឹងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ (**"SMD"**) ។ បណ្ដឹងឧទ្ធរណ៍១ (ដែលបានទទួលយល់ព្រមផងដែរ តាមរយៈសេចក្ដីយោងធ្វើឡើងដោយជនត្រូវចោទអៀង សារី) អះអាង នៅក្នុងចំណោមរឿងរ៉ាវផ្សេងៗទៀតថា សហចៅក្រមស៊ើបអង្កេត បានរំលោភលើអនុវិធាន៥៥.៥ នៃវិធានផ្ទៃក្នុង តាមរយៈការប្រើប្រាស់គោលការណ៍នៃភាពគ្រប់គ្រាន់មួយ, ពួកគេមានកាតព្វកិច្ចស៊ើបសួរទៅលើ SMD ហើយថា ពួកគេមានសិទ្ធិទទួលបានសវនាការមួយដែលគ្មានការពន្យារពេលសមរម្យដែលជាការបដិសេធ ចំពោះជនត្រូវចោទពីការទទួលបាននូវការជំនុំជម្រះដោយយុត្តិធម៌ និងថាពួកគេមានកំហុសឆ្គងនៅក្នុងការរកឃើញមួយដែលថា សំណើដើមមានភាពមិនច្បាស់លាស់ ។ ចំណែកបណ្ដឹងឧទ្ធរណ៍២ ជនត្រូវចោទ អៀង សារី អះអាងបន្ថែមក្នុងចំណោមការអះអាងដទៃទៀតថា សហចៅក្រមស៊ើបអង្កេត បានបង្ហាញនូវយុទ្ធវិធីមូលដ្ឋានមិនត្រឹមត្រូវមួយចំពោះភារកិច្ចរបស់ខ្លួន នៅក្នុងកិច្ចស៊ើបសួរដោយអនាគតិ ។

២. សហព្រះរាជអាជ្ញា ដាក់ចម្លើយតបរួមបញ្ចូលគ្នាមួយទៅនឹងបណ្ដឹងឧទ្ធរណ៍ ដូចដែលបញ្ហានានាដែលលើកឡើងនៅក្នុងបណ្ដឹងឧទ្ធរណ៍ គឺមានលក្ខណៈដូចគ្នាបេះបិទ ឬក៏ជាន់គ្នាភាគច្រើន ហើយបណ្ដឹងឧទ្ធរណ៍២ លាយបញ្ចូលគ្នាជាមួយបណ្ដឹងឧទ្ធរណ៍១ តាមរយៈសេចក្ដីយោង ។

៣. អង្គបុរេជំនុំជម្រះ អាចបដិសេធចោលបណ្ដឹងឧទ្ធរណ៍១ មួយផ្នែក ថាមិនអាចទទួលយកបាននៅក្នុងវិសាលភាពមួយដែលបណ្ដឹងឧទ្ធរណ៍នេះត្រូវបានដាក់ដោយជនត្រូវចោទ ខៀវ សំផន ។ ជនត្រូវចោទ មិនមែនជាភាគីម្នាក់ក្នុងចំណោមភាគីនានាដែលបានដាក់សំណើដើម ដែលជាប្រធានបទនៃដីកាសម្រេចនេះទេ និងក៏មិនប៉ះពាល់ដោយផ្ទាល់ដោយដីកាសម្រេចនេះដែរ ហេតុដូច្នេះ អាចមិនមានសិទ្ធិប្ដឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចនេះទេ ។

៤. សហព្រះរាជអាជ្ញា ស្នើដល់អង្គបុរេជំនុំជម្រះបដិសេធចោលបណ្តឹងឧទ្ធរណ៍ ដោយសំអាងទៅលើទឡ្ហីករណ៍ដូចតទៅ៖

ក. ដើមបណ្តឹងឧទ្ធរណ៍បានខកខានក្នុងការបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេតបានបកស្រាយនិងប្រើប្រាស់អំណាចរបស់ពួកគេដោយមិនត្រឹមត្រូវ ដើម្បីបំពេញកិច្ចស៊ើបសួរស្វែងរកការពិត និងកាតព្វកិច្ចរបស់ពួកគេដើម្បីអនុវត្តកិច្ចស៊ើបសួរដោយគ្មានភាពលំអៀងអំពីថាតើភស្តុតាងជាការដាក់ឬដោះបន្ទុក ។ សហចៅក្រមស៊ើបអង្កេតបានបកស្រាយអំពីកាតព្វកិច្ចរបស់ពួកគេដោយត្រឹមត្រូវ ដើម្បីរុករកប្រភពភស្តុតាងពាក់ព័ន្ធទាំងអស់ រួមទាំងឯកសារនានានៅក្នុង SMD ផង ។

ខ. ដើមបណ្តឹងឧទ្ធរណ៍បានខកខានក្នុងការបង្ហាញឱ្យឃើញថា សហចៅក្រមស៊ើបអង្កេតបានអនុវត្តសិទ្ធិទទួលបានសវនាការមួយដែលគ្មានការពន្យារពេលសមរម្យ ដែលជាការធ្វើឱ្យខូចដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់ជនត្រូវចោទ ។

គ. សហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋានចុងក្រោយយ៉ាងត្រឹមត្រូវថា ដើមបណ្តឹងឧទ្ធរណ៍ខកខានមិនបានបំពេញតាមលក្ខខណ្ឌនានាដែលពាក់ព័ន្ធ និងដែលជាចំណុចចំៗភ្ជាប់ទៅនឹងសំណើសុំនេះ តាមរយៈការមិនបានបញ្ជាក់ឱ្យបានជាក់លាក់នូវហេតុផលដែលជាដើមអាទិ៍ និងភាពពាក់ព័ន្ធនៃសំណើដើម ដែលសុំឱ្យបំពេញកិច្ចកិច្ចស៊ើបសួរនោះ ។

ឃ. សហចៅក្រមស៊ើបអង្កេត បានសន្និដ្ឋានចុងក្រោយយ៉ាងត្រឹមត្រូវថា ការបង្ហាញកាតព្វកិច្ចដែលបានលើកឡើងដោយដើមបណ្តឹងឧទ្ធរណ៍ ត្រូវបានបំពេញ តាមរយៈការដាក់សំភារៈឯកសារទាំងអស់នៅលើសំណុំរឿង (ដែលមេធាវីការពារក្តីមានសិទ្ធិទទួលបានជាហូរហែរមក) ដែលធ្វើឡើងដើម្បីស្វែងរកការពិត មិនថាជាភស្តុតាងនោះ ជាភស្តុតាងសម្រាប់ដាក់ឬដោះបន្ទុកទេ និងថា មេធាវីការពារក្តីមានសិទ្ធិស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរជាក់លាក់ដែលពួកគេអាចបង្ហាញឱ្យឃើញថា គឺពិតជាធ្វើឡើងដើម្បីបញ្ជាក់អំពីការពិត ដោយឈរលើមូលដ្ឋាននៃកិច្ចស៊ើបសួរបឋម ។

៥. ក្នុងវិសាលភាពមួយ សហព្រះរាជអាជ្ញាមានទស្សនៈយល់ឃើញថា សហចៅក្រមស៊ើបអង្កេតមានការពឹងផ្អែកមួយចំណែកទៅលើគោលការណ៍នៃភាពគ្រប់គ្រាន់ មិនមែនជាការត្រឹមត្រូវ នោះសហព្រះរាជអាជ្ញាស្នើឱ្យអង្គបុរេជំនុំជម្រះ ពិចារណាបន្ថែមហេតុផលរបស់ពួកគេ ឬដាក់បញ្ចូលហេតុផលទាំងនោះជំនួសមូលហេតុដែលបានចង្អុលបង្ហាញនៅក្នុងសេចក្តីសន្និដ្ឋានចុងក្រោយ ។

## សេចក្តីសង្ខេបនៃអង្គហេតុ និងប្រវត្តិនីតិវិធីដែលពាក់ព័ន្ធ

៦. SMD ត្រូវបានបង្កើតឡើង បន្ទាប់ពីមានការបើកកិច្ចស៊ើបសួរតាមផ្លូវតុលាការនេះ ដើម្បីជាវេទិការអេឡិចត្រូនិចទូទៅធម្មតាមួយ សម្រាប់ការប្រមូលឯកសារទូទៅ និងឯកសារសំខាន់ជាសក្តានុពលនានា ត្រូវបាន "ចែករំលែក" រវាងការិយាល័យសហចៅក្រមស៊ើបអង្កេត និងគូភាគីនៃកិច្ចដំណើរការនីតិវិធី[1] ។ វាជាឧបករណ៍សម្រាប់ជួយសម្រួល ប្រហាក់ប្រហែលនឹងបណ្ណាល័យអេឡិចត្រូនិចអញ្ចឹងដែរ ដែលអ្នកចូលរួមអាចប្រើប្រាស់ដើម្បីស្រាវជ្រាវសំភារៈដែលអាចនឹងនាំដល់ការបញ្ជាក់អំពីការពិតលើបញ្ហាទាំងឡាយណាដែលស្ថិតនៅក្នុងកិច្ចស៊ើបសួររបស់តុលាការ[2] ។ ប្រសិនបើមានឯកសារណាមួយត្រូវបានស្គាល់អត្តសញ្ញាណ ឬត្រូវបាននាំឱ្យមានការយកចិត្តទុកដាក់ពីសហចៅក្រមស៊ើបអង្កេត (មិនថានៅក្នុង SMD ឬនៅកន្លែងណាផ្សេងទៀតទេ) ឯកសារទាំងនោះអាចត្រូវបានគេដាក់នៅក្នុងសំណុំរឿង ។ ដោយសារវាមិនមែនជាផ្នែកនៃកិច្ចស៊ើបសួរជាផ្លូវការ SMD ត្រូវបានគេដាក់ឱ្យងាយរកបានដោយបុគ្គលផ្សេងទៀត ដូចជាបុគ្គលិកនៃផ្នែកគាំពារការការពារក្តី[3] មិនមែនត្រឹមតែចៅក្រម និងគូភាគីប៉ុណ្ណោះទេ ។

៧. តាមសំណើបន្ទាន់មួយ ចុះថ្ងៃទី២០ ខែមេសា ឆ្នាំ២០០៩ ក្រុមមេធាវីការពារក្តីរបស់ អៀង ធីរិទ្ធ, នួន ជា និង អៀង សារី បានស្នើឱ្យសហចៅក្រមស៊ើបអង្កេត ពិនិត្យឡើងវិញលើគ្រប់ឯកសារទាំងអស់នៅលើ SMD, បង្កើតរបាយការណ៍ពិស្តារពេញលេញមួយអំពីការវិភាគរបស់ខ្លួន និងផ្តល់បញ្ជី

[1] ពិធីសារស្តីពីឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ (ដែលអាចរកបានតាមរយៈវ៉ិបសាយ: http://zylab/Exe/ZyNET.exe?Client=Common+Collection&Init=1&ZyAction=ZyActionr), ត្រង់កថាខ័ណ្ឌទី១ ។

[2] ដដែលដូចខាងលើ, វាក្យខ័ណ្ឌ ក, កថាខ័ណ្ឌទី២ និង វាក្យខ័ណ្ឌ ខ, កថាខ័ណ្ឌទី៣ ។

[3] ដដែលដូចខាងលើ, វាក្យខ័ណ្ឌ ខ, កថាខ័ណ្ឌទី២ ។

សំភារៈដោះបន្ទុកដែលមានផ្ទុកនៅក្នុង SMD (“**សំណើ**”)[4] ។ ដូចបានកត់សំគាល់ក្នុង **សេចក្តីផ្តើម** សហចៅក្រមស៊ើបអង្កេត បានបដិសេធលើសំណើនេះនៅថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០០៩ ។

**បញ្ហាបឋម**

*ភាពអាចទទួលយកបាននៃបណ្តឹងឧទ្ធរណ៍របស់ ខៀវ សំផន*

៨. អង្គបុរេជំនុំជម្រះអាចពិចារណាថា ខៀវ សំផន មិនមានសិទ្ធិប្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាសម្រេចទេ ដោយសារគាត់មិនមែនជាភាគីមួយនៅក្នុងចំណោមភាគីដើមដែលប្តឹង ហើយអាចឱ្យគេតវ៉ាបានថា គាត់មិនទទួលការប៉ះពាល់ដោយផ្ទាល់ពីដីកាសម្រេចនេះទេ ។ ទោះបីអនុវិធាន៥៥.១០ នៃវិធានផ្ទៃក្នុងចែងថា ដីកាបដិសេធលើសំណើសុំបំពេញកិច្ចស៊ើបសួរ “ត្រូវជូនដំណឹងដល់ភាគី និងបើកផ្លូវប្តឹងឧទ្ធរណ៍” ហើយវិធាន៧៤ អនុញ្ញាតឱ្យគ្រប់ភាគីប្តឹងឧទ្ធរណ៍លើដីកាសម្រេចដែលស្ថិតនៅក្នុងជំពូកនេះក៏ដោយ ក៏បទប្បញ្ញត្តិទាំងនេះគួរតែត្រូវបានបកស្រាយថា ជាទូទៅ ដីកាសម្រេចបដិសេធសំណើសុំបំពេញកិច្ចស៊ើបសួរ អាចនឹងត្រូវប្តឹងឧទ្ធរណ៍បានចំពោះតែភាគីណាដែលធ្វើពាក្យសុំ តែប៉ុណ្ណោះ ។ វាអាចមានកាលៈទេសៈផ្សេងដែលជាការសមស្របសម្រាប់អង្គបុរេជំនុំជម្រះ ដើម្បីគិតគូរ លើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយភាគីដទៃផ្សេងទៀត ប្រសិនបើពួកគេបានទទួលរងផលប៉ះពាល់ដោយផ្ទាល់ពីដីកាសម្រេចនោះ[5] និងដែលត្រូវបានផ្តល់ឱកាសឱ្យប្តឹងឧទ្ធរណ៍ដោយអង្គជំនុំជម្រះ ។ ខៀវ សំផន មិនបានស្វែងរកឱកាសពីអង្គជំនុំជម្រះដើម្បីប្តឹងឧទ្ធរណ៍ទេ ហើយក៏មិនបានបញ្ជូនអំណះអំណាងណាមួយ ដើម្បីបង្ហាញឱ្យឃើញពីមូលហេតុដែលថា បណ្តឹងឧទ្ធរណ៍របស់គាត់គួរណាស់ត្រូវបានគេទទួលយក បើទោះបីជាគាត់មិនមែនជាភាគីនៃសំណើដើមក៏ដោយ ។ បើនិយាយតាមរបៀបផ្សេងវិញ ទោះជាបើកចំហរចំពោះរូបគាត់ឱ្យឆ្លើយតបទៅនឹងបណ្តឹងឧទ្ធរណ៍ក៏ដោយ ក៏គាត់បានជ្រើសរើសមិនប្រើប្រាស់នូវជម្រើសនេះដែរ ។

៩. វិធាន៧៤ មិនមានបំណងផ្តល់លទ្ធភាពដល់ភាគីឱ្យប្តឹងឧទ្ធរណ៍ទៅនឹងដីកាសម្រេច ដែលពួកគេមិនទទួលរងការប៉ះពាល់ដោយផ្ទាល់នោះទេ ។ សំណើដើមបានស្វែងរកឱ្យមានការចាប់ផ្តើមកំណត់

[4] សំណើរួមជាបន្ទាន់របស់មេធាវីការពារក្តី ស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ដើម្បីស្វែងរកភស្តុតាងដោះបន្ទុក ដែលផ្ទុកនៅក្នុងឃ្លាំងផ្ទុកឯកសាររួម (“SMD”) ។

[5] នោះគឺជាការបន្តតាមលំដាប់ពីបទបញ្ញត្តិនៃអនុវិធាន២១ និងមាត្រា៣៣ថ្មីនៃ*ច្បាប់ស្តីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការ។*

ទៅលើសំភារៈភស្តុតាងសម្រាប់ដោះបន្ទុក ទាក់ទងនឹងភាគីដែលដាក់ពាក្យប្តឹង (ជនត្រូវចោទអៀង ធីរិទ្ធ, នួន ជា និង អៀង សារី) ។ ខៀវ សំផន មិនមែនជាភាគីដែលដាក់ពាក្យប្តឹងទេ ហេតុដូច្នេះ សំណើមិនតម្រូវឲ្យសហចៅក្រមស៊ើបអង្កេត ចាត់វិធានការណាមួយទាក់ទងនឹងរូបគាត់ឡើយ ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះអាចសន្និដ្ឋានជាចុងក្រោយថា គាត់មិនមានផលប្រយោជន៍គ្រប់គ្រាន់ដើម្បីតវ៉ាអំពីភាពត្រឹមត្រូវនៃដីកាសម្រេចទេ ។

១០. តាមរបៀបផ្សេងពីនេះគួរតែបកស្រាយវិធាន៧៤ ថា អនុញ្ញាតឲ្យភាគីណាក៏បានដើម្បីប្តឹងឧទ្ធរណ៍លើគ្រប់ការបដិសេធនៃសំណើសុំកិច្ចស៊ើបសួរ ដើម្បីឲ្យភាគីណាមួយដែលមិនមែនជាភាគីដើមនៃបណ្តឹងទាមទារមិនចាំបាច់តម្រូវឲ្យបង្ហាញថា ភាគីនោះបានរងការប៉ះពាល់ពីដីកាសម្រេច ដែលខ្លួនកំពុងប្តឹងឧទ្ធរណ៍នោះទេ[6] ។ ដោយមានការពិចារណាអំពីអនុភាពនៃការធ្វើឲ្យខូចផលប្រយោជន៍ ដូចជា ការពង្រីកលទ្ធភាពផ្នែកបណ្តឹងឧទ្ធរណ៍ អាចនឹងនាំឲ្យមានចំពោះអំពើប្រព្រឹត្តិនៃកិច្ចដំណើរការនីតិវិធីប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌ និងហានិយភ័យជាផលវិបាកនៃការរំលោភ លើដំណើរការជាដើម ការបកស្រាយណាមួយបែបនេះមិនអាចថាជាបំណងរបស់អ្នកតាក់តែងវិធានផ្ទៃក្នុងឡើយ ។

១១. ជាចុងក្រោយ សហព្រះរាជអាជ្ញាកត់សំគាល់ឃើញថា ការបញ្ចូលបណ្តឹងឧទ្ធរណ៍ដែលមានការអះអាងដោយខៀវ សំផន នេះ ខកខានមិនបានអនុវត្តតាមលក្ខខណ្ឌតម្រូវនៃ *សេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក*[7] ទេ ដែលនៅក្នុងនោះ បណ្តឹងឧទ្ធរណ៍នេះត្រូវបានដាក់ជាភាសាខ្មែរ និងអង់គ្លេស ហេតុដូច្នេះ វាមិនមែនជាភាសាទាំងពីរដែលបានជ្រើសរើសដោយ ក្រុមមេធាវីការពារក្តីឲ្យ ខៀវ សំផន[8] ទេ ។ ទោះបីជាចុងក្រោយ វាមិនពាក់ព័ន្ធទៅនឹងលទ្ធផលនៃបណ្តឹងឧទ្ធរណ៍១ ក៏ដោយ ក៏ការមិនអនុវត្តន៍តាមដូច្នេះដោយក្រុមមេធាវីការពារក្តី គឺជារឿងចម្លែក ដោយសារថា កាលពីមុនពួកគេធ្លាប់បានតវ៉ារួចហើយថា វាមិនអាចឲ្យពួកគេចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីបានទេ ដរាបណាឯកសារទាំងអស់មិនត្រូវបានបកប្រែជាភាសាបារាំងនោះ ។

---

[6] តាមទ្រឹស្តី ការណ៍នេះគឺដោយសារថា ដូចដែលវិធាន៧៤ អនុញ្ញាតឲ្យគ្រប់ភាគីប្តឹងឧទ្ធរណ៍លើដីកាបដិសេធចំពោះសំណើសុំបំពេញកិច្ចស៊ើបសួរ ។

[7] សូមអានមាត្រា៧.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការដាក់ឯកសារនៅចំពោះមុខ អ.វ.ត.ក (អ.វ.ត.ក/០១/២០០៧/វិសោធនកម្មលើកទី៥) ។

[8] *សេចក្តីជូនដំណឹងរបស់មេធាវីរបស់ ខៀវ សំផន ស្តីពីការប្រើប្រាស់ភាសាក្នុងការដាក់ជូន និងទទួលឯកសារ*, ចុះថ្ងៃទី២ ខែមករា ឆ្នាំ២០០៨, លេខឯកសារ A114 ។

## *សវនាការផ្ទាល់មាត់គួរតែបានជៀសវាង*

១២. ដើមបណ្តឹងឧទ្ធរណ៍បានស្នើឱ្យមានសវនាការផ្ទាល់មាត់មួយលើបណ្តឹងឧទ្ធរណ៍ ។ ក្នុងខណៈដែលសហព្រះរាជអាជ្ញាបន្តគាំទ្រឱ្យមានសវនាការផ្ទាល់មាត់នៅចំពោះមុខអង្គបុរេជំនុំជម្រះ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បណ្តឹងឧទ្ធរណ៍ទាំងនេះមិនបានលើកពីបញ្ហាច្បាប់ដ៏ស្មុគស្មាញ ឬសំខាន់នានាទេ ហេតុដូច្នេះបណ្តឹងឧទ្ធរណ៍ទាំងនេះគួរតែបានសម្រេចដោយឈរលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ដើម្បីជាប្រយោជន៍នៃសេដ្ឋកិច្ចរបស់តុលាការ ។

១៣. កថាខ័ណ្ឌទី៧៧.៣.ខ នៃវិធានផ្ទៃក្នុង បានផ្តល់ឆន្ទានុសិទ្ធិដល់អង្គបុរេជំនុំជម្រះ ក្នុងការសម្រេចកំណត់ ទៅលើបណ្តឹងឧទ្ធរណ៍ ដោយផ្អែកទៅលើតែមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ បន្ទាប់ពីបានពិចារណាទៅលើទស្សនៈយល់ឃើញរបស់ភាគីរួចមក ។ នៅពេលមានការ ពាក់ព័ន្ធជាមួយនឹងសំណើមួយដើម្បីអនុវត្តឆន្ទានុសិទ្ធិនេះ អង្គបុរេជំនុំជម្រះបានពិចារណាពីពេលមុនៗ លើសារសំខាន់នៃបណ្តឹងឧទ្ធរណ៍[9] ។

១៤. ដើមបណ្តឹងឧទ្ធរណ៍ថ្លែងថា បណ្តឹងឧទ្ធរណ៍ទាក់ទងនឹងវិសាលភាពនៃកិច្ចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ។ ដើមបណ្តឹងឧទ្ធរណ៍សន្និដ្ឋានថា សវនាការមួយគួរតែបានកំណត់ពេលវេលាឡើង ដើម្បី “បំភ្លឺលើបញ្ហានេះ” ដែល “ស្ថិតនៅចំកណ្តាលនីតិវិធីរបស់ អ.វ.ត.ក” ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា បញ្ហានានាដែលមានក្នុងបណ្តឹងឧទ្ធរណ៍មិនធំទូលាយ ឬក៏មិនធំដុំ ដូចដែលដើមបណ្តឹងឧទ្ធរណ៍បានចោទប្រកាន់នោះទេ ប៉ុន្តែវាគ្រាន់តែមានលក្ខណៈសាមញ្ញនិងភាគច្រើនជាបញ្ហាបច្ចេកទេសតែប៉ុណ្ណោះ អាស្រ័យហេតុដូច្នេះហើយបានជាវាមានលក្ខណៈសមស្របសម្រាប់ការកំណត់ដោយផ្អែកលើមូលដ្ឋាននៃសេចក្តីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ។ បណ្តឹងឧទ្ធរណ៍ទាក់ទងជាចំបងនឹងបញ្ហានៃនីតិវិធីសម្រាប់ការអនុវត្តន៍ (ដែលគេហៅថា ការប្រើប្រាស់ត្រឹមត្រូវនៃយន្តការធ្វើសំណើសុំបំពេញកិច្ចស៊ើបសួរ និងស្ថានភាពនៃសំភារៈភស្តុតាងនៅខាងក្រៅសំណុំរឿង) និងមិនបានលាតត្រដាងពីចំណុចសំខាន់ៗណាមួយនៃច្បាប់ទេ ។

---

[9] *សាធារណៈ សេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា ដើម្បីកំណត់លើបណ្តឹងឧទ្ធរណ៍ដោយផ្អែកលើមូលដ្ឋាននៃសារណាជាលាយលក្ខណ៍អក្សរតែប៉ុណ្ណោះ និងដីកាកំណត់កាលបរិច្ឆេទសវនាការ,* ខៀវ សំផន, ០០២/១៩-០៩-២០០៧-អ.វ.ត.ក/ក.ស.ច.ស (អបជ១៥), ចុះថ្ងៃទី៦ ខែកុម្ភៈ ឆ្នាំ២០០៩, ឯកសារលេខ C26/5/13, កថាខ័ណ្ឌទី៧ ។

១៥. ខណៈដែលដើមបណ្ដឹងឧទ្ធរណ៍ចោទថា សហចៅក្រមស៊ើបអង្កេត បានយល់ខុសជាមូលដ្ឋានអំពីលក្ខណៈ និងវិសាលភាពនៃអំណាចស៊ើបសួររបស់សហចៅក្រមស៊ើបអង្កេត ការពិនិត្យឡើងវិញទៅលើសំណើ ដីកាសម្រេច និងបណ្ដឹងឧទ្ធរណ៍ លាតត្រដាងឱ្យឃើញថានេះមិនមែនជាករណីទេ។ លទ្ធផលនៃបណ្ដឹងឧទ្ធរណ៍អាស្រ័យលើចំណុចដ៏មានកំហិតបំផុតនៃការខ្វែងគំនិតគ្នា(តម្រូវការអំពីភាពជាក់លាក់នៃសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរនិងការយល់ដឹងអំពី "ភាពគ្រប់គ្រាន់") ដែលត្រូវបានគូសបញ្ជាក់យ៉ាងច្បាស់ និងអាចត្រូវបានសម្រេចកំណត់លើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ ។ ជាការបន្ថែម យុត្តិសាស្ត្រអន្តរជាតិ បង្ហាញឱ្យឃើញតែមួយចំនួនតូចប៉ុណ្ណោះនៃសេចក្ដីសម្រេចសង្ខេបនានារបស់តុលាការអន្តរជាតិ ដែលពាក់ព័ន្ធនឹងការដាក់បង្ហាញសំភារៈភស្តុតាងដោះបន្ទុក ហើយករណីយុត្តិសាស្ត្រ គឺមានលក្ខណៈត្រង់មិនស្មុគស្មាញទេ ។

១៦. ជាចុងក្រោយ ក្នុងដំណាក់កាលនៃកិច្ចស៊ើបសួរនេះ ការកំណត់សម្រេចជាបន្ទាន់លើបណ្ដឹងឧទ្ធរណ៍ដែលមានលក្ខណៈបន្ទាន់បន្ទំ គឺជាការសំខាន់ ។ ដូចដែលអង្គបុរេជំនុំជម្រះមិនមែនជាអ្នកប្រចាំការរបស់តុលាការ តាមចំណាត់ការនីតិវិធី"មាននៅលើតែក្រដាស" អង្គបុរេជំនុំជម្រះនឹងមានលទ្ធភាពកំណត់សម្រេចទៅលើបណ្ដឹងឧទ្ធរណ៍បានឆាប់រហ័ស ជាងអ្វីដែលខ្លួនត្រូវរង់ចាំរហូតដល់មានការកំណត់កាលបរិច្ឆេទសវនាការ មុននឹងធ្វើការសម្រេចទៅលើបណ្ដឹងឧទ្ធរណ៍ទាំងនេះ ។

## ក្របខ័ណ្ឌច្បាប់

### បទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ

*ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា*

១៧. មាត្រា ២៣ ថ្មី នៃ *ច្បាប់ស្ដីពីការបង្កើតឱ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ* មួយផ្នែក ចែងថា៖

"ប្រសិនបើនីតិវិធីដែលមានស្រាប់ពុំបានចែងពីករណីពិសេសមួយ ឬ ប្រសិនបើមានភាពមិនច្បាស់លាស់ក្នុងការបកស្រាយ ឬ អនុវត្តនីតិវិធីនោះ ឬប្រសិនបើមានបញ្ហាទាក់ទងទៅនឹងភាពសមស្របនៃនីតិវិធីទាំងនេះជាមួយបទដ្ឋានអន្តរជាតិ សហចៅក្រមស៊ើបអង្កេតអាចស្វែងរកការណែនាំក្នុងបទដ្ឋាននីតិវិធី ដែលបានបង្កើតឡើងក្នុងកម្រិតអន្តរជាតិ" ។

*ក្រមនីតិវិធីព្រហ្មទណ្ឌ*

១៨. មាត្រា ១២៧ នៃ *ក្រមនីតិវិធីព្រហ្មទណ្ឌ នៃ ព្រះរាជាណាចក្រកម្ពុជា* ចែងថា៖

"ចៅក្រមស៊ើបសួរ បំពេញកិច្ចស៊ើបសួរទាំងអស់ដែលខ្លួនយល់ឃើញថា មានប្រយោជន៍សម្រាប់បង្ហាញឲ្យឃើញការពិតដោយអនុលោមតាមច្បាប់ ។ ចៅក្រមស៊ើបសួរមានករណីយកិច្ចស៊ើបសួរទាំងដាក់បន្ទុក និងដោះបន្ទុក" ។

*វិធានផ្ទៃក្នុង*

១៩. អនុវិធាន៥៣.៤ នៃវិធានផ្ទៃក្នុង សម្រាប់ *អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា* ចែងថា៖

"ក្នុងរយៈពេលឆាប់ដែលអាចធ្វើទៅបាន សហព្រះរាជអាជ្ញា ត្រូវបង្ហាញទៅសហចៅក្រមស៊ើបអង្កេត នូវសំភារៈទាំងឡាយដែលសហព្រះរាជអាជ្ញាបានដឹង ហើយដែលសំភារៈទាំងនេះនឹងអាចនាំឲ្យគ្មានពិរុទ្ធភាព ឬសម្រាលពិរុទ្ធភាពនៃជនសង្ស័យ ឬជនត្រូវចោទ ឬធ្វើឲ្យប៉ះពាល់ដល់ភាពជឿជាក់នៃភស្តុតាងក្នុងការចោទប្រកាន់" ។

២០. អនុវិធាន៥៥.៥ នៃវិធានផ្ទៃក្នុង ក្នុងផ្នែកដែលពាក់ព័ន្ធ ចែងថា៖

"ក្នុងការដឹកនាំកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត អាចចាត់វិធានការស៊ើបសួរដែលនាំទៅរកការបង្ហាញការពិតដោយអនុលោមតាមច្បាប់។ ក្នុងគ្រប់ករណីទាំងអស់ សហចៅក្រមស៊ើបអង្កេត ត្រូវដឹកនាំកិច្ចស៊ើបសួរដោយអនាគតិ ទោះបីជាភស្តុតាងដែលនឹងរកបាននោះជាភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុកក៏ដោយ" ។

២១. អនុវិធាន៥៥.១០ នៃវិធានផ្ទៃក្នុង ចែងថា៖

"គ្រប់ពេលវេលានៃកិច្ចស៊ើបសួរ សហព្រះរាជអាជ្ញា ជនត្រូវចោទ ឬដើមបណ្តឹងរដ្ឋប្បវេណីអាចស្នើសុំឱ្យសហចៅក្រមស៊ើបអង្កេតចេញដីកា ឬ បំពេញកិច្ចស៊ើបសួរណាមួយដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការស៊ើបសួរ ។ ប្រសិនបើសហចៅក្រមស៊ើបអង្កេតមិនយល់ព្រម សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាបដិសេធឱ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន ហើយនៅគ្រប់ករណីទាំងអស់ ត្រូវចេញដីកានេះឱ្យបានមុនពេលបញ្ចប់កិច្ចស៊ើបសួរ ។ ដីកាសម្រេចនេះត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ភាគី ។ ដីកាបដិសេធនេះបើកផ្លូវប្តឹងឧទ្ធរណ៍" ។

២២. អនុវិធាន៦៦.១ នៃវិធានផ្ទៃក្នុង ក្នុងផ្នែកដែលពាក់ព័ន្ធ ចែងថា៖

"នៅពេលដែលសហចៅក្រមស៊ើបអង្កេតយល់ឃើញថា ការស៊ើបសួរត្រូវបានបញ្ចប់ សហចៅក្រមស៊ើបអង្កេតត្រូវជូនដំណឹងដល់គ្រប់ភាគី និងមេធាវីរបស់ភាគី ។ ភាគីទាំងអស់មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ ដើម្បីសុំឱ្យមានកិច្ចស៊ើបសួរបន្ថែម" ។

២៣. អនុវិធាន៦៧.៣ នៃវិធានផ្ទៃក្នុង ក្នុងផ្នែកដែលពាក់ព័ន្ធ ចែងថា៖

"សហចៅក្រមស៊ើបអង្កេតត្រូវចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម:

.......

គ- ពុំមានភស្តុតាងគ្រប់គ្រាន់ដើម្បីផ្តន្ទាទោសជនត្រូវចោទ" ។

*ការអនុវត្តន៍វគោលការណ៍អន្តរជាតិ*

២៤. ដោយសារតែ*ក្រមនីតិវិធីព្រហ្មទណ្ឌ* និង *វិធានផ្ទៃក្នុង* មិនបានចែងនិយមន័យច្បាស់លាស់អំពីកាតព្វកិច្ចរបស់ភាគីនានា ទាក់ទងអំពីភាពជាក់លាក់និងការពាក់ព័ន្ធនៃ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ ហើយនិងអំពីកម្រិតនៃភាពមិនប្រាកដប្រជាដែលអាចនឹងលេចឡើងពាក់ព័ន្ធនឹងកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត ប្រសិនជាមាន ដែលទាក់ទងទៅនឹងសំណើមិនជាក់លាក់ដែលសុំឱ្យស្វែងរកឯកសារដោះបន្ទុក ជាការសមស្របនោះគឺគួរតែស្វែងរកការណែនាំនៅក្នុងវិធាន និង

នៅក្នុងគោលការណ៍នានាដែលត្រូវបានគេបង្កើតឡើងនៅក្នុងកម្រិតអន្តរជាតិវិញ[10]។គោលការណ៍ទាំងនេះ បើសិនជាមានលក្ខណៈសមស្របនោះ គឺនឹងត្រូវបានធ្វើការពិចារណាដើម្បីជាការឆ្លើយតបទៅនឹងបញ្ហាជាក់លាក់ទាំងឡាយដែលដើមបណ្តឹងឧទ្ធរណ៍បានលើកឡើង ។

**ចម្លើយតបទៅនឹងចំណុចទាំងឡាយដែលបានលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍**

**សេចក្តីសង្កេតបឋមអំពីកាតព្វកិច្ចរបស់សហចៅក្រមស៊ើបអង្កេត**

២៥. ក្រោយពេលបានទទួលបណ្តឹងណាមួយស្តីពីសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ សហចៅក្រមស៊ើបអង្កេត ត្រូវមានភារកិច្ចក្នុងការស្វែងរកភស្តុតាងដែលអាចឱ្យបញ្ជាក់ការពិតបាន ទៅនឹងការចោទប្រកាន់ទាំងឡាយ ដូចដែលបានលើកឡើងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងក្នុងដីកាបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម[11] ។ ភារកិច្ចនេះ គឺត្រូវបំពេញដោយការចាត់វិធានការណ៍តាមដែលសហចៅក្រម*យល់ឃើញថា មានសារប្រយោជន៍ដើម្បីបញ្ជាក់ការពិត*[12] ហើយវិធានការណ៍បែបនេះអាចនឹងត្រូវបានផ្តួចផ្តើមគំនិតដោយសហចៅក្រម*ដោយមានមូលហេតុសមស្រប* ឬដោយមានសំណើជាក់លាក់ពីភាគីណាមួយក្នុងចំណោមភាគីទាំងអស់ ។ រីឯសហចៅក្រម គឺមានឆន្ទានុសិទ្ធិមួយដើម្បីសម្រេចអំពីថា តើសកម្មភាពនៃការស៊ើបសួរគួរចាត់វិធានការណ៍ដូចម្តេចខ្លះ? ដែលថាក្នុងការអនុវត្តនូវសិទ្ធិអំណាចរបស់តុលាការ គឺត្រូវតែអនុវត្តដោយគ្មានភាពលំអៀង ដោយផ្អែកលើអង្គហេតុនានា និងដោយអនុលោមទៅតាមច្បាប់[13] ។ សកម្មភាពនៃកិច្ចស៊ើបសួរដែលនាំឱ្យអាចបញ្ជាក់ការពិតបាន គឺត្រូវតែអនុវត្តដោយសត្យានុម័ត និងដោយមានការខិតខំប្រឹងប្រែងដូចៗគ្នា ទោះបីជាវាទំនងជានឹងនាំឆ្ពោះទៅរកការដាក់បន្ទុក ឬមួយក៏ដោះបន្ទុកក៏ដោយ[14] ។

---

[10] មាត្រា២៣(ថ្មី) នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

[11] អនុវិធាន៥៥.២ និង៥៥.៣ ។

[12] មាត្រា១២៧ នៃក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌរបស់ព្រះរាជាណាចក្រកម្ពុជា។

[13] គោលការណ៍ជាមូលដ្ឋាន ស្តីពីឯករាជ្យភាពរបស់តុលាការ ដែលត្រូវបានអនុម័តដោយសមាជលើកទី៧ របស់អង្គការសហប្រជាជាតិស្តីពីការទប់ស្កាត់ឧក្រិដ្ឋកម្ម និងប្រព្រឹត្តកម្មចំពោះជនល្មើស, ដែលបានធ្វើឡើងនៅទីក្រុងមីឡិន ពីថ្ងៃទី២៦ សីហា ដល់ទី ៦ កញ្ញា ១៩៨៥ និងត្រូវបានចុះហត្ថលេខាយល់ព្រមដោយសេចក្តីសម្រេចចិត្តរបស់មហាសន្និបាតអង្គការសហប្រជាជាតិ លេខ៤០/៣២ ចុះថ្ងៃទី២៩ វិច្ឆិកា ១៩៨៥ និងលេខ ៤០/១៤៦ ចុះថ្ងៃទី១៣ ធ្នូ១៩៨៥។ *សូមអានផងដែរនូវ* គោលការណ៍ Burgj ស្តីពីឯករាជ្យភាពនៃតុលាការអន្តរជាតិ ដែលមាននៅក្នុងគេហទំព័រ www.ucl.ac.uk/laws/cict/docs/burgh_final_21204. pdf), ត្រង់ទំព័រ១។

[14] អនុវិធាន ៥៥.៥។

២៦. សហព្រះរាជអាជ្ញា សន្និដ្ឋានថា នៅពេលដែលសហចៅក្រមស៊ើបអង្កេតមានការភាន់ច្រឡំនៅក្នុងការអនុវត្តគោលការណ៍ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាងនៅក្នុងទម្រង់ ដូចដែលមានចែងនៅក្នុងដីកាសម្រេច ទោះបីជាយ៉ាងណាក្តីក៏ពួកគេត្រូវតែអនុវត្តឱ្យបានត្រឹមត្រូវ នូវគោលការណ៍សំខាន់ៗខាងលើនេះដែរ ។ សហចៅក្រមស៊ើបអង្កេត បានធ្វើការបកស្រាយអំពីកាតព្វកិច្ចរបស់ខ្លួនបានសមស្របដោយការធ្វើសកម្មភាពដោយមិនលំអៀង ក្នុងការស្វែងរកយ៉ាងសកម្មទាំងឯកសារដាក់បន្ទុក និង ទាំងឯកសារដោះបន្ទុក ក៏ដូចជាអំពីលក្ខខណ្ឌតម្រូវសម្រាប់សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរថាត្រូវតែមានការពាក់ព័ន្ធ និងមានភាពជាក់លាក់គ្រប់គ្រាន់ ។

**"គោលការណ៍ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាង"**

**(បណ្តឹងឧទ្ធរណ៍ទី១-ហេតុផលទី១ និង បណ្តឹងឧទ្ធរណ៍ទី២ អំណះអំណាង ទី III (ក))**

២៧. បណ្តឹងឧទ្ធរណ៍ គឺសំដៅទៅលើសេចក្តីថ្លែងដូចតទៅនេះនៅក្នុងដីកាសម្រេចដែលក្នុងនោះ សហចៅក្រមស៊ើបអង្កេតស្នើសុំឱ្យប្រើគោលការណ៍ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាង ដែលដើមបណ្តឹងឧទ្ធរណ៍ពោលអះអាងថា មិនមានអត្ថិភាពនោះទេក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ។

> "ភាពសមហេតុសមផល ដែលបង្កើតបានជាមូលដ្ឋានទ្រទ្រង់ដល់ការស៊ើបសួរលើករណីរឿងព្រហ្មទណ្ឌណាមួយនោះគឺថា គោលការណ៍ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាង"ដែលមានប្រៀបលើគោលការណ៍មានភស្តុតាងទាំងអស់: ចៅក្រមស៊ើបអង្កេតណាមួយ អាចមានសិទ្ធិបិទកិច្ចស៊ើបសួរបាន ក្រោយពេលខ្លួនបានសម្រេចថាមានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់លើជនត្រូវចោទហើយនោះ" ។

អំពីគោលការណ៍ ឬលក្ខខណ្ឌតម្រូវនៃភាពគ្រប់គ្រាន់នៃភស្តុតាង ដីកាសម្រេចក៏បានចែងដែរថា៖

> "ដើម្បីបំពេញមុខងារអញ្ញាក្រឹតរបស់ខ្លួន គឺសហចៅក្រមស៊ើបអង្កេត មិនមានកាតព្វកិច្ចក្នុងការស្វែងរកដោយគ្មានរយៈពេលកំណត់នោះទេ (ដែលភាសាអង់គ្លេសហៅថា fishing expeditions *[ដែលមានន័យថាៈ ស្វែងរកដោយស្មានៗពីប្រភពជាច្រើនក្រែងលោមានឯកសារពាក់ព័ន្ធ ដូចវាវម្ជុលក្នុងបាតសមុទ្រ]*) ដើម្បីស្វែងរកឯកសារដោះបន្ទុកនោះទេ ដរាបណាសហចៅក្រមទាំងនោះបានបំពេញសព្វគ្រប់តាមលក្ខខណ្ឌតម្រូវ ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាង" ។ (លេខយោងជើងទំព័រត្រូវបានលុបចេញ)

ដីកាសម្រេចមិនបានយោងទៅលើបញ្ញត្តិច្បាប់ ឬតារាងច្បាប់យោងណាមួយ ឬក៏ ទៅលើលក្ខខណ្ឌតម្រូវអំពីភាពគ្រប់គ្រាន់នៃភស្តុតាងនោះទេ ។

២៨. សហព្រះរាជអាជ្ញា សូមជូនការសន្និដ្ឋានថា ការវែកញែកហេតុផលរបស់សហចៅក្រមស៊ើបអង្កេត គឺជាការខុស ព្រោះដោយសារវាមិនបានបំពេញគ្រប់គ្រាន់ឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវនៃគោលការណ៍ស្ដីពីភាពគ្រប់គ្រាន់នៃភស្តុតាងដែលបានលើកឡើងនោះទេ ។ ការលើកឡើងដោយមិនបានបំពេញគ្រប់គ្រាន់ឱ្យបានត្រឹមត្រូវតាមលក្ខខណ្ឌតម្រូវដែលថា កិច្ចស៊ើបសួរមួយអាចត្រូវបានបិទភ្លាម បន្ទាប់ពីមានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ហើយ គួបផ្សំគ្នាជាមួយនឹងសញ្ញាណមួយថា មានភាពគ្រប់គ្រាន់ដែលមានប្រៀបលើការមានភស្តុតាងទាំងអស់ (a notion that sufficiency overweighs exhaustiveness) គឺជាការមិនត្រឹមត្រូវនោះទេ ។ ក៏ប៉ុន្តែដូចដែលនឹងបង្ហាញឱ្យឃើញដូចខាងក្រោមនេះ តាមការយល់ឃើញនៅក្នុងបរិបទនេះ ការប្រើប្រាស់ "គោលការណ៍" នេះរបស់សហចៅក្រមស៊ើបអង្កេត នៅទីបំផុតគឺមិនមែនមានលក្ខណៈទូលំទូលាយដូចជាគោលការណ៍ដែលសម្រាប់ធ្វើយុត្តិកម្ម ចំពោះការបដិសេធនូវដីការសម្រេចណាមួយនោះទេ ។

២៩. នៅក្នុងសេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា បើសិនជាសំណើសុំឱ្យបំពេញកិច្ចស៊ើបសួរណាមួយមានការពាក់ព័ន្ធ និងមានលក្ខណៈជាក់លាក់គ្រប់គ្រាន់នៅក្នុងអ្វីដែលវាបានបង្ហាញឱ្យឃើញ *តែមួយក្រឡេកភ្នែក*ថា វិធានការណ៍ដែលបានស្នើសុំគឺនាំឱ្យអាចបង្ហាញការពិតបាននោះ សហចៅក្រមស៊ើបអង្កេតត្រូវតែយល់ព្រមលើសំណើនេះ ទោះបីជានៅមុនពេលទទួលសំណើនោះសហចៅក្រមស៊ើបអង្កេតអាចយល់ឃើញ ឬក៏មិនយល់ឃើញថា "មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់ហើយ" ក៏ដោយ។ នេះគឺជាករណី ឧទាហរណ៍ដូចជា បើសិនជាសំណើនេះត្រូវបានដាក់នៅមុនការផុតកាលកំណត់ដូចដែលបានចែងនៅក្នុងអនុវិធាន៦៦.១ ដែលចង្អុលបង្ហាញទៅលើភស្តុតាងថ្មីទៀត ដែលផ្ដល់ពន្លឺបន្ថែមលើបញ្ហាដែលកំពុងស្ថិតនៅក្នុងការស៊ើបសួរ និងធ្វើយុត្តិកម្មចំពោះវិធានការណ៍នៃការស៊ើបសួរជាបន្តទៀត ។ ក៏ប៉ុន្តែ នេះគឺមិនមែនមានន័យថា គោលការណ៍មួយមានប្រៀបលើនៃគោលការណ៍មួយទៀត (ភាពគ្រប់គ្រាន់នៃភស្តុតាងទល់នឹងការមានភស្តុតាងទាំងអស់) នោះទេ ក៏ប៉ុន្តែគ្រាន់តែថា សិទ្ធិអំណាចនៃការស៊ើបអង្កេតរបស់ចៅក្រម គឺបានទទួលមកដោយត្រឹមត្រូវ ។ វិធានផ្ទៃក្នុងបាន ចែងយ៉ាងច្បាស់ស្ដីពីការដាក់សំណើសុំឱ្យបំពេញកិច្ចស៊ើប

សួរបន្ថែមទៀត បន្ទាប់ពីចៅក្រមចេញសេចក្តីជូនដំណឹងមួយអំពីការសុំឱ្យបិទការស៊ើបសួរ (ដែលនៅត្រង់ចំណុចនេះ ចៅក្រមបានចាត់ទុកថា ការស៊ើបសួរត្រូវបានធ្វើសេចក្តីសន្និដ្ឋានរួចហើយ)[15]។

៣០. ក៏ប៉ុន្តែការវែកញែកហេតុផលរបស់សហចៅក្រមស៊ើបអង្កេត លើគោលការណ៍ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាង មិនគួរត្រូវបានធ្វើការបកស្រាយឱ្យខុសពីបរិបទនោះទេ ។ ដីកាសម្រេចមិនបានស្នើឱ្យគោលការណ៍នេះបង្រួមវិសាលភាពនៃការស៊ើបសួរឱ្យតូចចង្អៀតនោះទេ ហើយក៏មិនឱ្យគោលការណ៍នេះធ្វើយុត្តិកម្មចំពោះការបដិសេធនូវសំណើសុំកិច្ចស៊ើបសួរណាមួយផ្សេងពីនេះ ដែលមានសុពលភាពនោះដែរ។ សហចៅក្រមស៊ើបអង្កេតទទួលស្គាល់យ៉ាងច្បាស់លាស់ថា ភារកិច្ចរបស់ខ្លួនមិនត្រូវបានកំរិតត្រឹមតែការស្វែងរកភស្តុតាង ដើម្បីធ្វើការចោទប្រកាន់ជនត្រូវចោទប៉ុណ្ណោះទេ[16] និងបញ្ជាក់ថា ពួកគេកំពុងតែស្វែងរកក្នុងលក្ខណៈស្មើភាពគ្នាទាំងភស្តុតាងដាក់បន្ទុកនិងទាំងភស្តុតាងដោះបន្ទុក[17] ហើយនិងកំពុងតែធ្វើការរុករកយ៉ាងសកម្មនូវគ្រប់រាល់ប្រភពនៃឯកសារទាំងអស់ដែលតាមការយល់ឃើញរបស់ខ្លួនថា អាចនឹងមានប្រភេទឯកសារផ្សេងពីនេះទៀត ដែលអាចឱ្យបញ្ជាក់ការពិតបាន - ក្នុងនោះរួមទាំងឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុង កុំព្យូទ័រ (SMD) ផង ។ សហចៅក្រមស៊ើបអង្កេត ក៏បានថ្លែងបញ្ជាក់ថែមទៀតថា ៖

ក. ឯកសារណាមួយដែលបានបង្ហាញអត្តសញ្ញាណថា បានបំពេញសព្វគ្រប់តាមលក្ខណៈវិនិច្ឆ័យដែលតម្រូវអំពីការដែលអាចឱ្យបញ្ជាក់ការពិតបាន ទោះបីជាភស្តុតាងដាក់បន្ទុក ឬមួយក៏ដោះបន្ទុកក៏ដោយ គឺត្រូវបានដាក់បញ្ចូលជាក្លួណៈប្រព័ន្ធនៅក្នុងសំណុំរឿង, ហើយ

ខ. ប្រសិនជា ក្រោយពីការស្វែងរកជាបឋមរួច មេធាវីការពារក្តីចាប់ផ្តើមដឹងអំពីភស្តុតាងដែលពួកគេមានបំណងចង់ឱ្យសហចៅក្រមស៊ើបអង្កេតជ្រាប មេធាវីអាចមានសិទ្ធិជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេតអំពីភស្តុតាងនោះ ។ [១៧]

៣១. ជាការច្បាស់លាស់ណាស់ថា សហចៅក្រមស៊ើបអង្កេតមិនមានឆន្ទានុសិទ្ធដែលទាក់ទងនឹងភារកិច្ចរបស់ខ្លួនដែលត្រូវតែមិនមានភាពលំអៀង នៅក្នុងការស្វែងរកភស្តុតាងដែលអាចឱ្យបញ្ជាក់ការពិត

---

[15] អនុវិធាន៦៦.១។

[16] ដីកាសម្រេច កថាខណ្ឌទី១៥, ចំណុច១ និងចំណុច ៣។

[17] ដីកាសម្រេច កថាខណ្ឌទី១៥ ។

បាននោះទេ ហើយត្រូវតែធ្វើយ៉ាងដូច្នេះយ៉ាងសកម្ម និងដោយមានការយកចិត្តទុកដាក់ ទោះបីជាភស្តុតាងដែលនឹងលេចឡើងនោះមានលក្ខណៈជាការដាក់បន្ទុក ឬដោះបន្ទុកក៏ដោយ[18] ។ ក៏ប៉ុន្តែ សហចៅក្រមស៊ើបអង្កេត ពិតជាមានឆន្ទានុសិទ្ធិមែនក្នុងការកំណត់សម្រេចថាតើសកម្មភាពនៃការស៊ើបសួរអ្វីដែលអាចឱ្យបញ្ជាក់ការពិតបាន ដើម្បីឱ្យមានភាពច្បាស់លាស់ថាភារកិច្ចរបស់ខ្លួនដែលត្រូវធ្វើសកម្មភាពដោយមិនលំអៀងនោះមិនលាតសន្ធឹងរហូតទៅដល់តម្រូវឱ្យខ្លួនអនុវត្តសកម្មភាពក្នុងការស៊ើបសួរដែលអាចនឹងមានការស្នើសុំនោះទេ ដោយមិនគិតអំពីថា តើសំណើទាំងនោះត្រូវបានរៀបរាប់ទូលំទូលាយពេកឬដោយមិនច្បាស់លាស់របៀបណា ហើយដែលទីបំផុតគឺគ្មានប្រសិទ្ធភាពនោះទេ ។ ចំពោះរឿងនេះ ចៅក្រមបានថ្លែងបញ្ជាក់យ៉ាងត្រឹមត្រូវថា ពួកខ្លួនមាន "សិទ្ធិ ហើយក៏ថែមទាំងមានភារកិច្ច ដើម្បីធ្វើការបដិសេធលើសំណើសុំឱ្យបំពេញការស៊ើបសួរដែលដាក់ជូនដោយភាគីនានានៅពេលដែលខ្លួនយល់ឃើញថា សំណើទាំងនោះ គឺមិនអាចឱ្យបញ្ជាក់ការពិតបានទេ"[19] ។

៣២. បន្ទាប់ពីបានធ្វើការពិនិត្យពិចារណាលើគ្រប់ជ្រុងជ្រោយ សូមជូនការសន្និដ្ឋានថា ទោះបីជាមានការយោងទៅលើគោលការណ៍ស្តីពីភាពគ្រប់គ្រាន់នៃភស្តុតាងដែលនៅក្នុងដីកាសម្រេចនោះក៏ដោយ ក៏សហចៅក្រមស៊ើបអង្កេត បានយល់ឃើញដោយត្រឹមត្រូវ អំពីលក្ខណៈនៃកាតព្វកិច្ចនានារបស់ខ្លួន និងការវែកញែកហេតុផលរបស់ខ្លួននៅក្នុងដីកាសម្រេចនោះគឺមិនធ្វើយុត្តិកម្មចំពោះសេចក្តីសន្និដ្ឋានដូចដែលបានស្នើនៅក្នុងបណ្តឹងឧទ្ធរណ៍ថា សហចៅក្រមស៊ើបអង្កេតបានស្វែងរកដើម្បី បង្រួមវិសាលភាពនៅក្នុងការស៊ើបសួររបស់ខ្លួនឱ្យតូច ដោយមិនត្រឹមត្រូវទេ ។

## បណ្តឹងឧទ្ធរណ៍១ - ទឡ្ហីករណ៍ទី២: អំពី "ករណីយកិច្ច" ក្នុងការស៊ើបសួរ ទៅលើឯកសារក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រ (SMD)

៣៣. ដើមបណ្តឹងរដ្ឋប្បវេណីទាំងឡាយ ស្នើយកអនុវិធាន ៥៣.១ និង៥៣.២ មកសំអាងថា សហចៅក្រមស៊ើបអង្កេតត្រូវបាន "ដាក់" ដោយសហព្រះរាជអាជ្ញា អំពីឯកសារដែលនៅក្នុងឃ្លាំងផ្ទុក

[18] នោះគឺជាការបញ្ជាក់ច្បាស់ទាំងដោយអនុវិធាន៥៥.៥ និងដោយមាត្រា១២៧ នៃក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ។

[19] ដីកាសម្រេច ត្រង់កថាខណ្ឌទី១០ ។

ឯកសាររួមនៅក្នុងកុំព្យូទ័រ (SMD) ដែលហេតុដូចនេះ គឺត្រូវតែមានកាតព្វកិច្ចក្នុងការស៊ើបសួរ លើឯកសារទាំងនោះ ។ សហព្រះរាជអាជ្ញាសន្និដ្ឋានថា អំណះអំណាងនេះ គឺត្រូវបរាជ័យ ដោយសារការបកស្រាយបទបញ្ញត្តិខុសផង និងការយល់ខុសអំពីអង្គហេតុផង ។

៣៤. មានវិធីសាស្ត្រតែ២គត់ប៉ុណ្ណោះ ដែលអាចធ្វើឲ្យឯកសារចូលទៅក្នុងសំណុំរឿង ចាប់តាំងពីពេលបើកកិច្ចស៊ើបសួរតទៅ: ទី១ គឺដោយការដាក់ជូនជាផ្លូវការណ៍ នៅក្នុងពេលដែលបើកកិច្ចស៊ើបសួរ និងទី២ គឺដោយការដាក់បញ្ចូលជាបន្ទាប់មកទៀតដោយសហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿង ។ នៅក្រោមជម្រើសទី១ (ដែលពឹងផ្អែកលើអនុវិធាន៥៣.១ និង៥៣.២ នោះ ឯកសារនានា គឺត្រូវតែដាក់ជូនដោយសហព្រះរាជអាជ្ញា និងអមដោយដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (ព្រមជាមួយនឹងសំណុំរឿងផង) នៅក្នុងពេលដែលដាក់ឯកសារ ។ នេះគឺមិនដូចគ្នានិងក្នុងករណី ដែលមាននៅទីនេះនោះ[20] ដែលឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ (SMD) មិនត្រូវបាន "ដាក់ជូន" ជាមួយគ្នានិងដីកាកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដែលគាំទ្រដល់ការចោទប្រកាន់ទាំងឡាយដែលមាននៅក្នុងដីកានោះទេ ។ ឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ (SMD) ជាបន្ទាប់មកទៀត ក៏ត្រូវបានចូលជាផ្នែកនៅក្នុងសំណុំរឿងដែរ ។

៣៥. ឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ (SMD) គឺត្រូវបានបង្កើតឡើង ក្រោយពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដើម្បីឲ្យអ្នកដែលចូលរួមទាំងឡាយមានលទ្ធភាពអាចចូលទៅប្រើប្រាស់បានដោយសក្តានុពល នូវឯកសារទាំងឡាយដែលពាក់ព័ន្ធនៅក្នុងនោះបាន[21] ។ ដោយនៅក្នុងនោះមានប្រភពផ្សេងៗដែលបើកចំហរជាទូទៅនោះ តាមពិតឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រនេះ គ្មានអ្វីខុសប្លែកគ្នាពីបណ្ណាល័យមួយដែលមានឯកសារទាក់ទងទៅនឹងព្រឹត្តការណ៍ផ្សេងៗនៅក្នុងប្រទេសកម្ពុជា ក្នុងអម្លុងពេលដែលស្ថិតនៅក្នុងយុត្តាធិការពេលវេលារបស់តុលាការនេះនោះឡើយ ។ សហព្រះរាជអាជ្ញាបានថ្លែងថា ខ្លួនមិនបានដឹងអំពីវត្តមាននៃឯកសារដោះបន្ទុក នៅក្នុងឯកសារដែលមានក្នុងឃ្លាំងផ្ទុកឯកសាររួមក្នុងកុំព្យូទ័រនោះទេ

[20] ដីកាសម្រេច ត្រង់កថាខណ្ឌទី១៤ ។

[21] មានកម្រងឯកសារទូទៅមួយនៅក្នុង ឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ ត្រូវបាន "ចែករំលែក"ដោយសហចៅក្រមស៊ើបអង្កេតខ្លួនឯងផ្ទាល់: សូមមើលនៅក្នុង សេចក្តីពិពណ៌នាអំពីឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រនៅក្នុងគេហទំព័រតាមអ៊ីនធឺណិតរបស់តុលាការ នៅត្រង់អាសយដ្ឋាន http://zylab/Exe/ZyNET.exe?client=Common+Collection&Init=1&ZyAction=ZyActionr

ប៉ុន្តែខ្លួននៅតែទទួលស្គាល់ និងគោរពអនុវត្តតាមកាតព្វកិច្ចរបស់ខ្លួនអនុលោមតាមអនុវិធាន ៥៣.៤ ជាដដែល ទាក់ទងទៅនឹងឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួម នៅក្នុងកុំព្យូទ័រ (SMD) ឬ ឯកសារណាមួយផ្សេងទៀតដែលស្ថិតនៅក្រោម ការកាន់កាប់ ឬ ការត្រួតត្រារបស់ខ្លួន ។

៣៦. ដោយសំណើសុំបានទទួលស្គាល់ថា ឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ គឺមិនមែនជាយន្តការជាផ្លូវការមួយសម្រាប់បង្ហាញជូន ឬ ការដាក់ជូននូវភស្តុតាង[22] ។ ពិធីសារស្តីពីឯកសារនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័របានចែងថា ឯកសារទាំងឡាយដែលត្រូវបានដាក់បញ្ចូលនៅក្នុងឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ គឺជាឯកសារ "ក្រៅពីឯកសារដែលពាក់ព័ន្ធទៅនឹងការស៊ើបសួរដែលកំពុងតែដំណើរការដោយ ក.ស.ព ឬ កិច្ចស៊ើបសួរដោយសហចៅក្រមស៊ើបអង្កេត"[23]ហើយការដាក់បញ្ចូលឯកសារទាំងនេះនៅក្នុងឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ "គឺមិនលើកទោសតាមបែបណាមួយឲ្យជនទាំងនោះរួចផុតពីកាតព្វកិច្ចតាមផ្លូវច្បាប់ដែលពួកគេអាចមានណាមួយផ្សេងទៀត ទាក់ទងទៅនឹងឯកសារ និងការប្រើប្រាស់នូវឯកសារទាំងនោះ"[24] ។

៣៧. អាស្រ័យហេតុនេះ ឯកសារដែលនៅក្នុងឃ្លាំងផ្ទុកឯកសាររួមនៅក្នុងកុំព្យូទ័រ គឺមិនត្រូវបានបង្កើតឡើងដើម្បីបំពេញ ឬដើម្បីជៀសវាងនូវការទទួលខុសត្រូវសំខាន់ៗ របស់សហចៅក្រមស៊ើបអង្កេត ឬសហព្រះរាជអាជ្ញានោះទេ ហើយក៏មិនត្រូវបានគេប្រើប្រាស់តាមរបៀបនោះដែរ ។ សំណុំរឿងគឺជាសំណុំឯកសារជាផ្លូវការ សម្រាប់កិច្ចស៊ើបសួររបស់តុលាការ ដែលមេធាវីការពារក្តីអាចមានសិទ្ធិចូលទៅពិនិត្យមើលបានជាបន្តបន្ទាប់ ដោយការជូនដំណឹងជាបុគ្គលពាក់ព័ន្ធទៅនឹងឯកសារនីមួយៗដែលបានដាក់នៅក្នុងសំណុំរឿង ។ នេះគឺជាការជួយឲ្យពួកគេអាចមានលទ្ធភាពមើល និងតាមដានទៅលើការជឿនលឿនទៅមុខនៃកិច្ចស៊ើបសួរទាំងមូល និងឲ្យពួកគេបានទទួលដំណឹងអំពីអំពីសំណើពាក់ព័ន្ធ នឹងសំណើជាក់លាក់ផ្សេងៗដែលពួកគេខកខានមិនបានធ្វើនៅក្នុងឱកាសនេះ ។

**ទោះបីជាដីកាសម្រេចត្រូវបានអនុវត្តដោយមិនត្រឹមត្រូវអំពីសិទ្ធិត្រូវទទួលបាន**
**នូវការជំនុំជំរះក្តីដោយពុំមានការអូសបន្លាយដោយមិនត្រឹមត្រូវ**

---

[22] សំណើសុំ ត្រង់កថាខណ្ឌទី១៤ ។

[23] នៅក្នុងសំណើសុំដដែល ផ្នែក ក, កថាខណ្ឌទី២ ។

[24] នៅក្នុងសំណើសុំដដែល ផ្នែក ខ, កថាខណ្ឌទី៣ ។

**(បណ្តឹងឧទ្ធរណ៍ទី១-ហេតុផលទី៣ ។ បណ្តឹងឧទ្ធរណ៍ទី២ អំណះអំណាងទី III (ខ))**

៣៨. ក្នុងការដោះស្រាយចំពោះសារសំខាន់នៃលក្ខខណ្ឌតម្រូវជាក់លាក់ដែលភ្ជាប់ទៅនឹង សំណើសុំកិច្ចស៊ើបសួរ (ដែលលើកឡើងនៅក្នុងបណ្តឹងឧទ្ធរណ៍១-ហេតុផលទី៤ ដូចខាងក្រោមនេះ) ក្នុងបរិបទនៃសិទ្ធិត្រូវទទួលបាននូវការជំនុំជំរះក្តីដោយពុំមានការអូសបន្លាយដោយមិនត្រឹមត្រូវ សហចៅក្រមស៊ើបអង្កេតថ្លែងថា "សំណើសុំណាមួយដែលអាចមានផលវិបាកធ្វើឱ្យដំណើរការនៃនីតិវិធី មានការអូសបន្លាយ *អាច* ត្រូវបដិសេធចោល"[25] ។

៣៩. ដើមបណ្តឹងឧទ្ធរណ៍បានជជែកតវ៉ាថា នេះគឺជាការប្រើប្រាស់សិទ្ធិទទួលបាននូវការជំនុំជំរះក្តីដោយពុំមានការអូសបន្លាយដោយមិនត្រឹមត្រូវ ដើម្បីធ្វើជាយុត្តិកម្មចំពោះការរំលោភបំពានទៅលើសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងការស៊ើបអង្កេតមួយដែលពេញលេញ[26] ។ ក៏ប៉ុន្តែនេះ គឺជាការបកស្រាយដីកាសម្រេចដែលមិនត្រឹមត្រូវទេ ។

៤០. នៅក្នុងផ្នែកដែលពាក់ព័ន្ធនៃដីកាសម្រេច ចៅក្រមបានថ្លែងថា ជាផលវិបាកនៃលក្ខខណ្ឌតម្រូវនានា ដើម្បីជៀសវាងការអូសបន្លាយដោយមិនត្រឹមត្រូវ និង *ដើម្បីជៀសវាងកុំឱ្យមានគ្រោះថ្នាក់បណ្តាលមកពីការរំលោភបំពានទៅលើភាពត្រឹមត្រូវយុត្តិធម៌ក្នុងការជំនុំជម្រះក្តី*នោះ គឺសហចៅក្រមស៊ើបអង្កេតត្រូវតែបដិសេធចោលនូវសំណើសុំទាំងនេះបើសិនជាពួកគេយល់ឃើញថា សំណើសុំទាំងនេះមិនអាចបញ្ជាក់ការពិតបានទេ[27] ។ ហេតុដូចនេះ ដីកាសម្រេច (១) ដែលដាក់កាតព្វកិច្ចផ្សេងៗឱ្យអនុលោមទៅតាមសិទ្ធិទទួលបានការជំនុំជម្រះក្តីដោយត្រឹមត្រូវយុត្តិធម៌ និងសិទ្ធិទទួលការជំនុំជម្រះក្តីឆាប់រហ័សដោយមិនមានការអូសបន្លាយដោយមិនត្រឹមត្រូវ នៅក្នុងភាពដែលមានសិទ្ធិស្មើគ្នា និងដោយអនុវត្តកាតព្វកិច្ចទាំងនោះដោយសន្សឹមៗ និង (២) ស្វែងរកដើម្បីការពារនូវសិទ្ធិទាំងនោះដោយបដិសេធចោលនូវសំណើទាំងឡាយណាដែលមិនច្បាស់លាស់ និងមិនជាក់លាក់ ។

៤១. ជាងនេះទៅទៀតគឺជាការច្បាស់លាស់ណាស់ថា សហចៅក្រមស៊ើបអង្កេតមិនបានស្វែងរកសុំ នូវសិទ្ធិទាំងនេះដើម្បីដាក់កំរិតទៅលើភារកិច្ចរបស់ខ្លួនតាមតែទំនើងចិត្តនោះទេ ។ តាមពិតផ្ទុយពីនេះ

---

[25] ដីកាសម្រេច ត្រង់កថាខណ្ឌទី៩។

[26] បណ្តឹងឧទ្ធរណ៍ទី១ កថាខណ្ឌទី៣០ និង៣៣, បណ្តឹងឧទ្ធរណ៍ទី២ កថាខណ្ឌទី១១។

[27] ដីកាសម្រេច ត្រង់កថាខណ្ឌទី១០។

គឺជាការពិត ។ ជាបន្ថែមពីលើសេចក្តីថ្លែង (ដូចដែលបានកត់សំគាល់ នៅក្នុងកថាខណ្ឌទី៣០ ខាងលើ) ថា ពួកគេ*បានខិតខំរុករកយ៉ាងសកម្មគ្រប់ប្រភពឯកសារទាំងអស់ ដែលតាមការយល់ឃើញរបស់ខ្លួនថា ក្នុងនោះអាចនឹងមានឯកសារភស្តុតាង ដែលអាចឱ្យបញ្ជាក់ការពិតបាន* ដែលដាក់ភស្តុតាងបែបនេះជាលក្ខណៈប្រព័ន្ធ (ទោះបីជាដាក់បន្ទុកឬដោះបន្ទុកក៏ដោយ) នៅក្នុងសំណុំរឿង[28] សហចៅក្រមស៊ើបអង្កេតក៏ទទួលស្គាល់ដែរថា ពួកខ្លួនមិនត្រូវបានអនុញ្ញាតឱ្យធ្វើការជ្រើសរើសភស្តុតាងតាមទំនើងចិត្ត ឬក៏បដិសេធមិនព្រមចាត់វិធានការណ៍ ដែលអាចឱ្យបញ្ជាក់ការពិតបាននោះទេ[29]។ ជាការច្បាស់លាស់ណាស់ថា វិធីសាស្ត្រនេះគឺការពារនូវសិទ្ធិរបស់ដើមបណ្តឹងឧទ្ធរណ៍ក្នុងការទទួលបាននូវសវនាការជំនុំជំរះក្តី ដោយត្រឹមត្រូវយុត្តិធម៌ និងការស៊ើបអង្កេតពេញលេញមួយ ។

៤២. សហព្រះរាអាជ្ញា ជូនយោបល់ថា ការផ្តល់សំអាងខាងលើនេះ បង្ហាញពីការយល់ឃើញដ៏ត្រឹមត្រូវ និងពីការអនុវត្តន៍សិទ្ធិរបស់ជនត្រូវចោទ ។

**បណ្តឹងឧទ្ធរណ៍១ - ទឡ្ហីករណ៍ទី ៤៖ តើសំណើមានលក្ខណៈជាក់លាក់គ្រប់គ្រាន់ដែរឬទេ?**

៤៣. សំណើបានសុំឱ្យសហចៅក្រមស៊ើបអង្កេត ធ្វើការពិនិត្យឡើងវិញនូវឯកសារ*ទាំងអស់* ដែលបានដាក់នៅក្នុង SMD បង្កើតជារបាយការណ៍លម្អិតមួយអំពីការវិភាគរបស់ពួកគេ និងផ្តល់នូវបញ្ជីឯកសារដោះបន្ទុកដែលមាននៅ SMD[30] ។ ភាពទូទៅ និងកង្វះខាតនូវភាពជាក់លាក់ និងភាពទាក់ទងគ្នានៃសំណើនេះ គឺមានលក្ខណៈច្បាស់លាស់ណាស់ នៅពេលដែលគេពិចារណាថា មាតិកានៅក្នុង SMD មាន៖

ក. ខ្សែភាពយន្ត និងឯកសារនានាដែលទាក់ទងនឹងសម័យកម្ពុជាប្រជាធិបតេយ្យ ចំនួន ២០០ ដែលបានផលិតឡើងនៅក្រោយថ្ងៃ ៦ មករា ឆ្នាំ១៩៧៩ ។

---

[28] ដីកាសម្រេច ត្រង់កថាខណ្ឌទី១៥។

[29] ដីកាសម្រេច ត្រង់កថាខណ្ឌទី៧។

[30] សំណើ, កថាខ័ណ្ឌទី ២៥ ។

ខ. ឯកសារនានាដែលទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យ និង/ឬ បក្សកុម្មុយនីសកម្ពុជា ចំនួន ១៧,៦០៧ ឯកសារ ។

គ. សម្ភូហកម្ម (ការប្រមែប្រមូល) ដែលរៀបតាមកាលបរិច្ឆេទនៅជំនាន់កាលនោះ នូវប្រភពព័ត៌មានចំហរ និងរបាយការណ៍នៃបណ្ដាញសារព័ត៌មាននានា ដែលទាក់ទងនឹងកម្ពុជាប្រជាធិបតេយ្យ និងបញ្ហារួមបញ្ចូលគ្នាផ្សេងៗទៀត ចាប់តាំងពីខែមករា ឆ្នាំ១៩៧៥ ដល់ខែមករា ឆ្នាំ១៩៧៩ ។

ឃ. ឯកសារនានាដែលទាក់ទងនឹងកិច្ចការសាធារណៈ ។

ង. ឯកសារទូទៅរួមផងទៃទៀត ដែលមិនត្រូវគ្នាទៅនឹងប្រភេទទាំងឡាយខាងលើនេះ[31] ។

៤៤. ដូចបានបញ្ជាក់នៅក្នុងសេចក្ដីផ្ដើម សហចៅក្រមស៊ើបអង្កេត បានបដិសេធចោលនូវសំណើនេះ ដោយសារកង្វះខាតនូវភាពជាក់លាក់ និងភាពទាក់ទងគ្នា ។ ពួកគាត់បានធ្វើការសម្រេចយ៉ាងត្រឹមត្រូវ នៅពេលដែលមេធាវីការពារក្ដីបានធ្វើសំណើសុំឲ្យមានការបំពេញកិច្ចស៊ើបសួរ គាត់ត្រូវតែផ្ដល់ជូនឲ្យបានគ្រប់គ្រាន់អំពីព័ត៌មានជាក់លាក់ ដើម្បីបង្ហាញថាហេតុអ្វីបានជាគាត់ជឿជាក់ថាសំណើមួយបែបដូច្នោះ ជាការមួយដ៏សមហេតុផល[32] ។

៤៥. លក្ខខណ្ឌតម្រូវនៃភាពជាក់លាក់ និងភាពទាក់ទងគ្នា ដែលភ្ជាប់ទៅនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរបានកើតឡើងយ៉ាងច្បាស់មកពីលក្ខណៈវិនិច្ឆ័យ ដែលកិច្ចស៊ើបសួរទាំងនោះត្រូវតែនាំទៅរកការបង្ហាញការពិត[33] ។ ដើម្បីទទួលបាននូវអំណាចសហចៅក្រមស៊ើបអង្កេតឲ្យបានត្រឹមត្រូវក្នុងការបំពេញកិច្ចស៊ើបសួរ ភាគីត្រូវតែបង្ហាញអំពីភាពទាក់ទងនៃកិច្ចស៊ើបសួរនោះ ទៅនឹងការចោទប្រកាន់នានានៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ហើយលើកសំណើរបស់ខ្លួនជា ស័ក្ដជាក់លាក់ (ឧ. ដោយការចង្អុលចំៗទៅកាន់ទីកន្លែង និងប្រភេទនៃភស្តុតាង) ដើម្បីឲ្យចៅក្រមអាច

[31] ការពិពណ៌នានៅក្នុងឃ្លាំងផ្ទុកឯកសាររួមអំពីគេហទំព័រផ្ទៃក្នុង (Intranet page) របស់អង្គជំនុំជម្រះ, នៅត្រង់ http://zylab/Exe/ZyNET.exe?Client=Common+Collection&Init=1&ZyAction=ZyActionr ។

[32] ដីកាសម្រេច, កថាខ័ណ្ឌទី ១១ និង ១៥ (ចំណុចទី ៤) ។

[33] អនុវិធាន ៥៥.៥ និង ៥៥.១ ។

វាយតម្លៃលើសំណើ និងបំពេញកិច្ចនោះទៅតាមរបៀបមួយដែលមានប្រសិទ្ធិភាព ។ សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ មិនអាចគ្រាន់តែសុំឱ្យចៅក្រមចាប់អនុវត្តគំរោងការស្រាវជ្រាវ មួយដែលមានទម្រង់សង្ខេបដ៏ទូលំទូលាយ មិនខុសគ្នាពីអ្វីទៅនឹងការសុំឱ្យពួកគាត់ពិនិត្យឡើងវិញនូវបណ្ណាល័យណាមួយក៏ដោយនៅក្នុងពិភពលោក ដែលអាចនឹងមានផ្ទុកនូវឯកសារពាក់ព័ន្ធទៅនឹងព្រឹត្តិការណ៍នៅក្នុងប្រទេសកម្ពុជា ក្នុងអំឡុងយុត្តាធិការពេលវេលារបស់អង្គជំនុំជម្រះនេះ ។

៤៦. បណ្តឹងឧទ្ធរណ៍នានា បានយោងទៅដល់ការសម្រេចរបស់អង្គបុរេជំនុំជម្រះ ទៅលើអត្ថន័យនៃស័ព្ទ "សំណើសុំឱ្យបំពេញកិច្ចស៊ើបសួរ"(ដែលអង្គបុរេជំនុំជម្រះបានឱ្យនិយមន័យថា "សំណើសុំបំពេញកិច្ចស៊ើបសួរគឺក្នុងគោលបំណងប្រមូលភស្តុតាង ដែលនាំដល់ការលាតត្រដាងការពិត")[34] ។ យ៉ាងណាក៏ដោយ និយមន័យនោះគឺត្រូវគ្នាទៅនឹងរបៀបដែលសហចៅក្រមស៊ើបអង្កេតបានធ្វើការបកស្រាយអំពីកាតព្វកិច្ចរបស់ខ្លួនទាក់ទងនឹងសំណើនោះ ។ អត្ថន័យដែលអង្គបុរេជំនុំជម្រះបានផ្តល់ឱ្យមិនបានលាតសន្ធឹងទៅដល់សំណើនានាដែលសុំឱ្យបំពេញ*កិច្ចស៊ើបសួរណាមួយ*នោះឡើយ ដែលជាទ្រឹស្តីអាចនាំឱ្យមានការរកឃើញនូវព័ត៌មានពាក់ព័ន្ធដោយមិនគិតអំពីថាតើ ទំហំនៃកិច្ចស៊ើបសួរនោះអាចនឹងមានទំហំប៉ុនណានោះទេ ។

៤៧. តាមទស្សនៈទាន នៅក្នុងវិសាលភាពមួយដែលវាមានការទាក់ទងនឹងការបង្ហាញនូវឯកសារដោះបន្ទុកនៅក្នុងសម្ភូហកម្ម ដែលអង្គភាពណាមួយនៃអង្គជំនុំជម្រះនេះអាចមានសំណើ គឺស្រដៀងគ្នាទៅនឹងការដាក់ញត្តិដោយក្រុមមេធាវីការពារក្តីនៅចំពោះមុខតុលាការអន្តរជាតិ*ពិសេស*ដោយចោទប្រកាន់ថា ភស្តុតាងដោះបន្ទុកក្រៅពីភស្តុតាងដែលបានដាក់បង្ហាញរួចហើយ នោះគឺស្ថិតនៅក្នុងការកាន់កាប់របស់ ឬការត្រួតពិនិត្យរបស់រដ្ឋអាជ្ញា ។ នៅពេលដែលភាពសំខាន់នៃតួនាទីរបស់ រដ្ឋអាជ្ញា កំពុងស្ថិតនៅក្នុងការស្រាវជ្រាវយ៉ាងសកម្ម ហើយការដាក់បង្ហាញនូវភស្តុតាងដោះបន្ទុក (ដូចដែលសហចៅក្រមស៊ើបអង្កេត ធ្លាប់បានធ្វើទៅតាមករណីយកិច្ចរបស់ខ្លួនកន្លងមក) តុលាការ បានទទួលយកនូវវិធីសាស្ត្រនេះ នៅក្នុងការដោះស្រាយនូវសំណើរបៀបនេះរបស់មេធាវីការពារក្តី៖

[34] *សាលដីកាលើបណ្តឹងឧទ្ធរណ៍របស់លោក ខៀវ សំផន ប្រឆាំងនឹងដីកាសម្រេចស្តីពីសិទ្ធិ និង កាតព្វកិច្ចរបស់ភាគីទាក់ទងនឹងការបកប្រែ,* ខៀវ សំផន, ០០២/១៩-០៩-២០០៧-អវតក/កសចស (អបជ-១១), ថ្ងៃទី២០ កុម្ភៈ ២០០៩, ឯកសារលេខ A190/I/20, កថាខណ្ឌទី ២៨ ។

ក. មេធាវីការពារក្ដីត្រូវដាក់ជូននូវ ភស្តុតាងឃើញមួយក្រឡេកភ្នែក ដោយស្នើថា វាទំនងជាភស្តុតាងដោះបន្ទុក ហើយកំពុងស្ថិតនៅក្នុងការកាន់កាប់របស់រដ្ឋអាជ្ញា[35] ។

ខ. អយ្យការត្រូវបានរំពឹងថានឹងបំពេញករណីយកិច្ចរបស់ខ្លួន ដោយសុទ្ធចិត្ត ហើយតុលាការត្រូវតែសន្មតថា អយ្យការកំពុងធ្វើយ៉ាងដូច្នេះ លើកលែងតែមានភស្តុតាងខ្លះដែលមានលក្ខណៈផ្ទុយ (ជាប្រយោជន៍ដើម្បីឱ្យដីកាមួយបង្គាប់បង្ខំឱ្យរដ្ឋអាជ្ញាបង្ហាញភស្តុតាងដោះបន្ទុកអាចនឹងត្រូវបានពិចារណា តែនៅពេលណាដែលមេធាវីការពារក្ដីអាច នឹងយល់ព្រមទៅនឹងតុលាការថា អយ្យការខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួន)[36] ។

៤៨. នៅពេលអនុវត្តគោលការណ៍ទាំងនេះទៅក្នុងទម្រង់ការនីតិវិធីរបស់ អ.វ.ត.ក សហចៅក្រមស៊ើបអង្កេត ត្រូវបានគេរំពឹង និងត្រូវតែបានសន្មតជាមុនថាបានធ្វើសកម្មភាព ដោយសុទ្ធចិត្តនៅក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ។ ការសន្មតជាមុននេះអាចជជែកសំអាងរឹតតែបានខ្លាំងក្លានៅអ.វ.ត.កជាងនៅក្នុងករណីនៃតុលាការ*ពិសេស* ទៅទៀត (ដែលការស៊ើបអង្កេតស្ថិត នៅក្នុងរង្វង់សមត្ថកិច្ចរបស់រដ្ឋអាជ្ញា) ដោយហេតុថាការិយាល័យសហចៅក្រមស៊ើបអង្កេតជាអង្គភាពតុលាការឯករាជ្យមួយ ហើយសហចៅក្រមស៊ើបអង្កេត មិនមែនជាភាគីនៅក្នុងដំណើរការនីតិវិធីនោះឡើយ ។

៤៩. បើដើមបណ្ដឹងឧទ្ធរណ៍ ស្វែងរកធ្វើការចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេត មិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរកឱ្យបានសកម្ម និងដាក់ជូនភស្តុតាងដោះបន្ទុក ដូច្នេះ ការអនុវត្តន៍គោលការណ៍អន្តរជាតិដែលពាក់ព័ន្ធ ពួកគាត់ត្រូវតែដាក់ជូននូវ ភស្តុតាងឃើញមួយក្រឡេកភ្នែកដែលថាភស្តុតាងបែបនោះមានអត្ថិភាព និងថាវាស្ថិតនៅក្នុងការកាន់កាប់ ឬក្នុងលទ្ធភាពអាចទទួលបានរបស់សហចៅក្រមស៊ើបអង្កេត ។ ទាំងសំណើ និងបណ្ដឹងឧទ្ធរណ៍មិនបានធ្វើយ៉ាងដូច្នោះទេ ។

---

[35] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើផលិតកម្មឯកសារដែលបានស្រាវជ្រាវរកឃើញ, ថ្ងៃទី២៧ មករា ១៩៩៧, កថាខណ្ឌទី ៥០.២ ។ *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សាលដីកាលើបណ្ដឹងឧទ្ធរណ៍, ថ្ងៃទី២៩ កក្កដា ២០០៤, កថាខណ្ឌទី ២៦៨ ។

[36] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, *រដ្ឋអាជ្ញា ទល់នឹង Brdjanin,* សេចក្ដីសម្រេចរបស់អង្គជំនុំជម្រះសាលាឧទ្ធរណ៍ លើញត្តិរបស់ដើមបណ្ដឹងឧទ្ធរណ៍សុំឱ្យមានការដាក់បង្ហាញ អនុលោមតាមវិធាន ៦៨ និងញត្តិសុំឱ្យមានដីកាបង្គាប់ទៅក្រឡាបញ្ជី ឱ្យបង្ហាញឯកសារជាក់លាក់មួយចំនួន, ថ្ងៃទី០៧ ធ្នូ ២០០៤, ទំព័រទី ២ និង ៣ ។

៥០. ជាសេចក្តីសន្និដ្ឋាន សហចៅក្រមស៊ើបអង្កេតធ្វើបានត្រឹមត្រូវក្នុងការបដិសេធសំណើនោះចោល ។ ជនជាប់ចោទ មិនអាចគេចរួចពីលក្ខខណ្ឌតម្រូវមូលដ្ឋាននានានៃភាពទាក់ទង និងភាពជាក់លាក់ ដោយការបញ្ជូនសំណើដ៏ទូលំទូលាយដោយមិនមានហេតុផលសមរម្យបានទេ ដែលការណ៍នេះគឺជា ការខកខានមិនបានបង្ហាញថាកិច្ចដែលបានស្នើសុំទាំងនោះ ត្រូវនាំទៅរកការបង្ហាញការពិតទេ ។

**បណ្តឹងឧទ្ធរណ៍១ - ទឡ្ហីករណ៍ទី ៥៖ការអនុវត្តន៍បមាណីច្បាប់អង់គ្លោ-សាក់សុងដែលបានចោទប្រកាន់**

៥១. ដើមបណ្តឹងឧទ្ធរណ៍បានសំអាងថា សេចក្តីយោងមួយនៅក្នុងដីកាសម្រេច ដែលយោងទៅដល់ សេចក្តីសម្រេចនានានៃតុលាការ*ពិសេស* ស្តីពីបញ្ហានៅក្នុងសំណើដែលសុំឱ្យបង្ហាញឯកសារដោះ បន្ទុក បាននាំទៅរកការអនុវត្តន៍បមាណីមួយដែលខុសឆ្គង ដែលថាគោលការណ៍នោះបានពិពណ៌នា នៅក្នុងសេចក្តីសម្រេចទាំងឡាយដែលមានលក្ខណៈជា"គោលការណ៍ច្បាប់អង់គ្លោ-សាក់សុងច្រើន ជាងគោលការណ៍ច្បាប់ច្បាប់ស៊ីវិល"[37] ។ ក្រៅពីសេចក្តីថ្លែងជាទូទៅមួយនេះ បណ្តឹងឧទ្ធរណ៍ខក ខានមិនបានពន្យល់ថាតើ ហេតុអ្វីបានជាសេចក្តីសម្រេចនានារបស់តុលាការអន្តរជាតិ មិនមានការ ទាក់ទងគ្នានោះទេ ។

៥២. យុត្តិសាស្ត្ររបស់តុលាការ បានធ្វើគោលសង្ខេបនៃវិធានទូទៅពាក់ព័ន្ធនឹងការដាក់បង្ហាញឯកសារ ដោះបន្ទុកដោយអង្គភាពស៊ើបអង្កេត ហើយបានចាត់លក្ខខណ្ឌតម្រូវអប្បបរមា សម្រាប់សំណើ របស់មេធាវីការពារក្តី នៅក្នុងករណីដែលមានការចោទប្រកាន់អំពី ការមិនប្រព្រឹត្តតាម ។ សូម្បីតែ ការទុកដោយឡែកនូវអង្គហេតុដែលថា តុលាការមិនអនុវត្តប្រព័ន្ធច្បាប់អង់គ្លោ-សាក់សុង ក៏ប៉ុន្តែ គ្រាន់តែបានអនុវត្តនូវនីតិវិធីសួរតទល់ ដែលតាមពិតទៅ គឺបានដាក់បញ្ចូលគ្នានូវទិដ្ឋភាពនានានៃ ប្រព័ន្ធច្បាប់ស៊ីវិល (ដូចជាអវត្តមាននៃវិធានដ៏ទូលំទូលាយស្តីពីភស្តុតាងជាដើម)[38] ក៏ដោយក៏គោល ការណ៍ទូទៅនៃនីតិវិធីព្រហ្មទណ្ឌ ដែលតុលាការទាំងនោះបានបង្កើតឡើង គឺមានការទាក់ទងគ្នា យ៉ាងច្បាស់លាស់ ។ គោលការណ៍ទាំងនេះ ត្រូវបានបង្កើតឡើងក្នុងកំរិតអន្តរជាតិដែល អ.វ.ត.ក ត្រូវបានតម្រូវឱ្យពិចារណានៅក្នុងកាលៈទេសៈដូចជាយ៉ាងនេះ[39] ។

---

[37] បណ្តឹងឧទ្ធរណ៍ទី ១, កថាខ័ណ្ឌទី ៤០ ។

[38] តុលាការក៏មិនអនុវត្តផងដែរនូវវិធាននៃភស្តុតាងរបស់ជាតិ: សូមមើល វិធាន ៨៩ នៃវិធាននៃភស្តុតាង និងនីតិវិធី, តុលាការព្រហ្មទណ្ឌ អន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី ។

[39] មាត្រា ២៣ (ថ្មី) នៃ *ច្បាប់ស្តីពីការបង្កើតឱ្យមាន អ.វ.ត.ក* ។

៥៣. នៅពេលដែលលើកឡើងអំពីភាពខុសគ្នាស្រឡះទ្វេភាគ (dichotomy) នៃច្បាប់អង់គ្លោ-សាក់សុង/ច្បាប់ស៊ីវិល ដើមបណ្តឹងឧទ្ធរណ៍នានាហាក់ដូចជាយល់ច្រឡំអំពីជំហររបស់មេធាវីការពារក្តី នៅក្នុងប្រព័ន្ធទាំងពីរនេះ ។ ពួកគាត់បានពោលអះអាងថា គោលការណ៍នានាដែលតុលាការ*ពិសេស*បានបង្កើតឡើងមិនអនុវត្តចំពោះប្រព័ន្ធច្បាប់ស៊ីវិលទេ នៅពេលដែល "មេធាវីការពារក្តីត្រូវបានដាក់ឱ្យនៅក្រៅ [ដំណើរការនៃការស៊ើបសួរ]"[40] ។ បើដើមបណ្តឹងឧទ្ធរណ៍ ទាំងនោះមានប្រាថ្នាចង់លើកឡើងនូវការដាក់មេធាវីការពារក្តីនៅ អ.វ.ត.ក "ឱ្យនៅក្រៅ" ដំណើរការនៃការស៊ើបសួរដែលខ្លួនបានចោទប្រកាន់នោះ ថាជាមូលហេតុមួយក្នុងការធ្វើឱ្យយុត្តិសាស្ត្រនៃតុលាការអន្តរជាតិមានភាពខុសគ្នានោះ គឺពួកគាត់បានលើកឡើងនូវសំអាងមួយដែលធ្វើឱ្យខ្លួនឯងចុះចាញ់ ពីព្រោះថាការដាក់មេធាវីការពារក្តី"ឱ្យនៅក្រៅ"ការស៊ើបអង្កេតគឺមានលក្ខណៈប្រហាក់ប្រហែលគ្នាមែនទែនទៅនឹងការស៊ើបអង្កេតនៅតុលាការអន្តរជាតិ ។ យ៉ាងណាក៏ដោយ សំអាងនេះ មិនចាំបាច់ត្រូវដេញដោលតទៅទៀតទេ ដោយសារតែមានការស្តែងឡើងនូវកង្វះខាតខាងតក្កវិជ្ជានៅក្នុងការស្នើឡើងថា អ.វ.ត.ក មិនត្រូវយកចិត្តទុកដាក់ចំពោះវិធាននានានៅកំរិតអន្តរជាតិ ដោយគ្រាន់តែមកពីភាគីមួយបានស្វែងរកនូវការដាក់ឱ្យប្រើប្រាស់ផ្លាកច្បាប់អង់គ្លោ-សាក់សុង ឬច្បាប់ស៊ីវិល នៅក្នុងតុលាការមួយនោះទេ ។

៥៤. ភាពខុសគ្នារវាងទម្រង់ការនៃនីតិវិធីនៅ អ.វ.ត.ក និងនៅតុលាការអន្តរជាតិពិតជាបានគាំទ្រដល់សំអាងមួយដែលថា កាតព្វកិច្ចរបស់មេធាវីការពារក្តីទាក់ទងនឹងសំណើសុំឯកសារដោះបន្ទុក នៅចំពោះមុខ អ.វ.ត.ក គឺមានលក្ខណៈសមហេតុសមផលទាំងស្រុង ។ ច្បាប់លក្ខន្តិកៈរបស់តុលាការអន្តរជាតិ និងវិធានស្តីពីភស្តុតាង និងនីតិវិធី បានផ្តល់ជូនដល់មេធាវីការពារក្តីនូវការបានចូលដល់ក្នុងអង្គភាពស៊ើបអង្កេតបានតិចតួចជាង នៅក្នុងករណីដែលបានចូលដល់ក្នុងដំណើរការនីតិវិធី នៅចំពោះមុខ អ.វ.ត.ក ហើយតុលាការទាំងនោះតម្រូវឱ្យមេធាវីការពារក្តីដាក់ជូននូវ ភស្តុតាងឃើញមួយក្រឡេកមើល អំពីអត្ថិភាពនៃភស្តុតាងដោះបន្ទុក នៅពេលមាន ដីកាសម្រេចឱ្យធ្វើការដាក់បង្ហាញ[41] ។ នៅក្នុងការស៊ើបសួរតាមច្បាប់ស៊ីវិល មេធាវីការពារក្តីអាចជជែកសំអាងដោយជំហរមួយដែលមានលក្ខណៈអនុគ្រោះ(ជាងនៅក្នុងការស៊ើបអង្កេតដែលធ្វើឡើងដោយរដ្ឋអាជ្ញា) ពីព្រោះ

---

[40] បណ្តឹងឧទ្ធរណ៍ទី ១, កថាខ័ណ្ឌទី ៤១ ។

[41] តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី, *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សេចក្តីសម្រេចរបស់អង្គជំនុំជម្រះសាលាដំបូង លើផលិតកម្មឯកសារដែលបានស្រាវជ្រាវរកឃើញ, ថ្ងៃទី២៧ មករា ១៩៩៧, កថាខណ្ឌទី ៥០.២ ។ *រដ្ឋអាជ្ញា ទល់នឹង Blaskic,* សាលដីកាលើបណ្តឹងឧទ្ធរណ៍, ថ្ងៃទី២៩ កក្កដា ២០០៤, កថាខណ្ឌទី ២៦៨ ។

ថា កិច្ចស៊ើបសួរត្រូវបានធ្វើឡើងដោយអង្គភាពស៊ើបសួរមួយដែលបាន ផ្ដល់ដល់មេធាវីការពារក្ដីនូវការទទួលបានទាំងស្រុងនូវសំណុំរឿងរបស់ខ្លួន ជាហេតុធ្វើឱ្យពួកគាត់ អាចមើលឃើញនូវគ្រប់និងរាល់ភស្ដុតាងនីមួយៗដែលត្រូវបានប្រមូលនិងជឿជាក់ ហើយនិងធ្វើសំណើជាក់លាក់ដើម្បីសុំឱ្យបំពេញកិច្ចស៊ើបសួរ ។ ដូច្នេះ គឺផ្ទុយគ្នាឆ្ងាយពី "ការដាក់ឱ្យនៅក្រៅ", មេធាវីការពារក្ដី គឺជាអ្នកចូលរួមម្នាក់ដែលសកម្មយ៉ាងខ្លាំងក្នុងកិច្ចស៊ើបសួរ តាមច្បាប់ស៊ីវិល បើទោះបីជាសិទ្ធិអំណាចទាំងស្រុងក្នុងការបំពេញកិច្ចស៊ើបសួរជាផ្លូវការ ត្រូវស្ថិតនៅលើចៅក្រមស៊ើបអង្កេតក៏ដោយ ។

៥៥. បើនេះពិតជាករណីនោះមែន ដូច្នោះវាជាការច្បាស់ណាស់ដែលថា បមាណីអប្បបរមា ដែលតុលាការ*ពិសេស* បានបង្កើតឡើង ទាក់ទងនឹងសំណើរបស់មេធាវីការពារក្ដីអំពីភស្ដុតាងដោះបន្ទុកគឺអាចអនុវត្តបានស្រដៀងគ្នាទៅនឹងសំណើនានាដោយមេធាវីការពារក្ដី នៅក្នុងដំណើរការនីតិវិធីនៅចំពោះមុខ អ.វ.ត.ក ។ ដូចដែលសហព្រះរាជអាជ្ញា បានដាក់ជូនរួចហើយ បើសិនជាមេធាវីការពារក្ដីត្រូវបានតម្រូវឱ្យៈ ទី១) ធានាថាសំណើសុំបំពេញកិច្ចស៊ើបសួររបស់ខ្លួន មានលក្ខណៈជាក់លាក់ និងមានភាពទាក់ទងគ្នា និងទី២) ដាក់ជូន ភស្ដុតាងឃើញមួយក្រឡេកភ្នែក ដែលគាំទ្រដល់ការចោទប្រកាន់ណាមួយក៏ដោយដែលថា សហចៅក្រមស៊ើបអង្កេត ខកខានមិនបានស្វែងរកនូវការដាក់បង្ហាញភស្ដុតាងដោះបន្ទុក ដែលនេះជាលក្ខខណ្ឌតម្រូវអប្បបរមា ដែលមេធាវីការពារក្ដីអាចធ្វើតាមបានយ៉ាងងាយស្រួលបំផុតដោយហេតុថា អាចមានមធ្យោបាយចូលដល់ការស៊ើបសួរបានយ៉ាងគ្រប់គ្រាន់ ដែលជាការមួយដែលពួកគាត់បានប្រឹងប្រែងចង់ឱ្យមាន ។

៥៦. តាមរយៈការថ្លែងថា មេធាវីការពារក្ដីអាចនឹងទទួលធ្វើការស្វែងរកបឋម នៅក្នុងឯកសារដែលកំពុងមានស្រាប់ ហើយជូនដំណឹងដល់សហចៅក្រមស៊ើបអង្កេត នោះពួកគាត់ត្រូវតែមានបំណងក្នុងការនាំយកនូវភស្ដុតាងជូនជាដំណឹងដល់ពួកគាត់[42] ពេលដែលមិនមាននិរាករណ៍លើការទទួលខុសត្រូវដើម្បីទទួលធ្វើការស៊ើបអង្កេតមួយដ៏ហ្មត់ចត់ និងមិនលំអៀង នោះសហចៅក្រមស៊ើបអង្កេត បានអនុវត្តយ៉ាងត្រឹមត្រូវនូវគោលការណ៍អន្តរជាតិ នៅក្នុងបរិបទនៃទម្រង់ការនីតិវិធីរបស់ អ.វ.ត.ក ។ តាមការពិត ដីកាសម្រេចបានស្នើឡើងនូវវិធីសាស្ត្រដែលនៅក្នុងនោះមេធាវីការពារក្ដីអាចប្រើប្រាស់បានយ៉ាងមានប្រសិទ្ធិភាពនូវ SMD តាមរយៈការចង្អុលបង្ហាញថា គ្រប់ឯកសារទាំងអស់ត្រូវបានធ្វើកំព្យូទ័រកម្ម ហើយថា ការស្វែងរករបស់ពួកគេអនុញ្ញាតឱ្យមាននូវ "ការស្វែង

[42] ដីកាសម្រេច, កថាខណ្ឌទី ១៥ ។

រកអត្ថបទទាំងមូលបានយ៉ាងឆាប់រហ័ស ប្រកបទៅដោយថាមពល ក៏ដូចជាការច្រោះរកនូវប្រភេទផ្សេងៗដទៃទៀតដែរ"[43] ។ នេះធ្វើឱ្យមានភាពងាយស្រួលសម្រាប់ភាគីក្នុងការស្វែងរកនូវភស្តុតាងដែលពួកគេបានពិចារណាថា មានការពាក់ព័ន្ធ និងដើម្បីដាក់ស្នើជូនទៅចៅក្រមពិចារណា ។

៥៧. នៅពេលដែលបច្ចុប្បន្ននេះ មានសហចៅក្រមស៊ើបអង្កេត និងសហព្រះរាជអាជ្ញា បានប្រើប្រាស់នូវ SMD នោះគ្រប់ភាគីទាំងអស់ក៏អាចនឹងប្រើប្រាស់បានដូចគ្នាដែរ ដោយរួមបញ្ចូលទាំង មេធាវីការពារក្តីផង ។ មេធាវីការពារក្តី មានសេរីភាពគ្រប់គ្រាន់ក្នុងការមិនព្រមធ្វើខ្លួនឯងឱ្យមានលទ្ធភាពអាចនឹងប្រើប្រាស់បាននូវគ្រឿងទាំងនេះ ហើយអាចនឹងធ្វើការជ្រើសរើសមិនយកនូវការដាក់បន្ថែមទៅក្នុងឯកសារទូទៅទាំងនោះ ដែលពួកគាត់អាចនឹងមានបានតាមចិត្តចង់របស់ពួកគាត់ ។ យ៉ាងណាក៏ដោយ បើសិនជាពួកគាត់ស្នើឱ្យ សហចៅក្រមស៊ើបអង្កេត ធ្វើការបំពេញកិច្ចស៊ើបសួរនានាដែលពួកគាត់បាននិយាយថា នឹងនាំឱ្យមានជាលទ្ធផល នៅក្នុងការដាក់ភស្តុតាងបន្ថែមចូលទៅក្នុងសំណុំរឿង នោះពួកគាត់ត្រូវតែធ្វើឱ្យត្រូវទៅតាមលក្ខខណ្ឌតម្រូវនៃភាពជាក់លាក់ និងភាពទាក់ទងដូចដែលបានពិភាក្សានៅក្នុងផ្នែក បណ្តឹងឧទ្ធរណ៍១ - ទឡ្ហីករណ៍ទី ៤ ។

## សេចក្តីសន្និដ្ឋាន

៥៨. ជាសេចក្តីសន្និដ្ឋាន សហព្រះរាជអាជ្ញា ស្នើឱ្យ សហចៅក្រមស៊ើបអង្កេត បដិសេធសំណើនោះចោលឱ្យបានត្រឹមត្រូវ និងស្នើឱ្យ អង្គបុរេជំនុំជម្រះ បដិសេធបណ្តឹងឧទ្ធរណ៍ទាំងនោះចោល ។

៥៩. ដោយការពិចារណាទៅលើបញ្ហាដែលបានលើកឡើង តាមរយៈការយោងទៅដល់ដីកាសម្រេចលើគោលការណ៍នៃភាពគ្រប់គ្រាន់ សហព្រះរាជអាជ្ញា សន្និដ្ឋានថា វាជាការត្រឹមត្រូវសម្រាប់ឱ្យអង្គបុរេជំនុំជម្រះ ដាក់ជំនួស (ឬ បន្ថែមទៅលើ) ការពិចារណារកហេតុផល នៅក្នុងដីកាសម្រេចដោយស្ថិតនៅក្នុងវិសាលភាពមួយ ដែលការពិចារណានោះយោងទៅដល់គោលការណ៍នោះ ដោយមានការពិចារណារកហេតុផលថាៈ

ក. នៅក្នុងការបំពេញករណីយកិច្ចរបស់ពួកខ្លួន ដើម្បីប្រព្រឹត្តដោយមិនមានភាពលំអៀង និងដើម្បីធ្វើការស្វែងរកនូវភស្តុតាងដាក់បន្ទុក និងភស្តុតាងដោះបន្ទុក សហចៅក្រមស៊ើបអង្កេត មានឆន្ទានុសិទ្ធិមួយក្នុងការកំណត់ថាតើកិច្ចស៊ើបសួរណាមួយ ដែលនាំទៅរកការ

[43] ដីកាសម្រេច, កំណត់សម្គាល់ជើងទំព័រលេខ ១៥ ។

បង្ហាញការពិត ។ គេត្រូវតែសន្មតទុកជាមុនថា ពួកគាត់នឹងបំពេញកិច្ចការដោយសុទ្ធចិត្ត ដោយគ្មានវត្តមានភស្តុតាងទាំងឡាយណាដែលមានលក្ខណៈផ្ទុយទេ ។

ខ. សហចៅក្រមស៊ើបអង្កេត មិនត្រូវបានតម្រូវឱ្យធ្វើការស្វែងរកនូវព័ត៌មានណាមួយ និងព័ត៌មានទាំងអស់ណាដែលអាចមានការទាក់ទងជាទ្រឹស្តី និងមានសិទ្ធិក្នុងការបដិសេធចោលនូវ សំណើនានាដែលពួកគេបានរកឃើញថា មិនបាននាំទៅរកការបង្ហាញការពិត ដោយសារព័ត៌មានទាំងនោះឥតបានការ មានលក្ខណៈទូទៅ មិនជាក់លាក់ ច្រំដែល ឬ មិនមានការទាក់ទងគ្នា ។

គ. ភាគីដែលស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរ ត្រូវទទួលបន្ទុកក្នុងការបង្ហាញថាសកម្មភាពនោះបាននាំទៅរកការបង្ហាញការពិត និងត្រូវតែធ្វើយ៉ាងដូច្នេះ ដោយធានាថាសំណើរបស់ខ្លួនមានលក្ខណៈជាក់លាក់និងទាក់ទងគ្នាយ៉ាងគ្រប់គ្រាន់សម្រាប់ចាត់វិធានការទៅតាមនោះ។

ឃ. ភាគីដែលបានចោទប្រកាន់ថា សហចៅក្រមស៊ើបអង្កេត ខកខានមិនបានបំពេញកាតព្វកិច្ចរបស់ខ្លួនក្នុងការស្វែងរក ឬដាក់បង្ហាញនូវភស្តុតាងដាក់បន្ទុក ឬភស្តុតាងដោះបន្ទុក ត្រូវតែធ្វើការដាក់ជូននូវ ភស្តុតាងឃើញមួយក្រឡេកភ្នែក ក្នុងលក្ខណៈជាភស្តុតាងជាក់លាក់ ដើម្បីជាការបង្ហាញថាភស្តុតាងនោះ គឺស្ថិតនៅក្នុងការកាន់កាប់របស់សហចៅក្រមស៊ើបអង្កេត ឬថាបើពុំដូច្នោះសោតទេ ត្រូវធ្វើការចង្អុលបង្ហាញអំពីទីតាំងរបស់វា ។

ង. សហចៅក្រមស៊ើបអង្កេតអាចនឹងធ្វើការបិទកិច្ចស៊ើបសួរនៅពេលដែលពួកគាត់ពិចារណាទៅឃើញថា តម្រូវការទាំងអស់នៃកិច្ចស៊ើបសួរបាននាំទៅរកការបង្ហាញការពិត អំពីការចោទប្រកាន់ទាំងឡាយ ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ និងងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរួចហើយ ។

ច. ក្នុងដំណាក់កាលនោះ (ថាតើ គេរកបានភស្តុតាងគ្រប់គ្រាន់ក្តី ឬមិនមានភស្តុតាងគ្រប់គ្រាន់ក្តីក្នុងការបញ្ជូនជនត្រូវចោទទៅជំនុំជម្រះ) សហចៅក្រមស៊ើបអង្កេត ត្រូវពិចារណាទៅលើសំណើបន្ថែមទៀតដែលត្រូវបានដាក់ជូនដោយស្របទៅតាមអនុវិធាន ៦៦.១ ។

00360958



D164/3/2

ឆ. បើសិនជា សហចៅក្រមស៊ើបអង្កេត បានរកឃើញថាសំណើបន្ថែមបែបដូច្នោះនឹង នាំទៅរកការបង្ហាញការពិត នៅក្នុងអ្វីដែលសំណើបន្ថែមនោះនឹងនាំទៅរកការរកឃើញនូវភាពខុសគ្នាដ៏សំខាន់ ឬជាការបន្ថែមទៅនឹងភស្តុតាងដែលមានមូលដ្ឋាននៅលើព័ត៌មានដែលបានប្រមូលរួចហើយ សហចៅក្រមស៊ើបអង្កេត ត្រូវមានករណីយកិច្ចចាត់វិធានការទៅតាមសំណើបន្ថែមនោះ ។

| **កាលបរិច្ឆេទ** | **ឈ្មោះ** | **ទីកន្លែង** | **ហត្ថលេខា** |
|---|---|---|---|
| ថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៩ | លោក យ៉េត ចរិយា<br>**សហព្រះរាជអាជ្ញារង** | ភ្នំពេញ | [signature and stamp] |
| | លោក William SMITH<br>**សហព្រះរាជអាជ្ញា** | ភ្នំពេញ | [signature] |